# និរាសនគរវត្ត

ចំណងជើងសៀវភៅ៖ និរាសនគរវត្ត
អ្នកនិពន្ធ៖ ឧកញ៉ា សុត្តន្តប្រីជាឥន្ទ
កាលបរិច្ឆេទបោះពុម្ព៖ ១៩៣៤
ទីកន្លែងបោះពុម្ព៖ ភ្នំពេញ
បោះពុម្ពផ្សាយដោយ៖ ព្រះរាជបណ្ណាល័យកម្ពុជា កម្ពុជសុរិយា
ខ្សែទី៖ ៧ ៨ ៩

៙និរាសរតន៍វត្តនគរសែនរចិត្ត
កាលចេញចាកលោកចរសមរមិត្រ    កែវជីវាគូជីវិតភិសម័យ។

ដោយមានការចក្រពង្សវង្សក្រស័ត្រ    ស៊ីសុវត្ថិព្រះកែវហ្វាសុឡាឡៃ
ព្រះចៅក្រុងកម្ពុជាធិបតែ    មានព្រះទ័យហ្នាយប៉ងពោធិញ្ញាណ។

ទ្រង់យាងមកនគរវត្តសមោសរ    ចាត់បដិសង្ខរណ៍ទីបូរាណ
បរិច្ចាគរាជទ្រព្យប្រដាប់ទាន    បំពេញញាណសម្ពោធិបញ្ញា។

កំណត់ថ្ងៃយាងនោះចុះខាងខ្នើត    ប្រាំបួនកើតភទ្របទមាសា
ថ្ងៃព្រហស្បតិ៍លេខ៥ឆ្នាំរកា    ពេលសុរិយាជ្រេសែងព្រះរង្សី ។

លោកចៅហ្វាយខែត្រស្រុកព្រះដំបង    ជានាយកងចាត់ការរាជការថ្មី
ព្រមទាំងលោកកុម្មីសែរអធិបតី    ចិត្តភក្តីត្រេកត្រង់ទាំងទ្វេហា។

រៀបចាត់ចែងតែងតួតាមទំនួល    ទៅទទួលព្រះចមចៅច័ក្រា
លោកក៏យកខ្ញុំបាទទៅផងណា    ព្រោះមេត្តាចង់ឲ្យយល់ទីបូរាណ។

គ្រាន់នឹងខឹតទទឹងប្រសាសន៍លោក    ក្រែងជួនស្មោកកើតទោសមោះដល់ប្រាណ
ខំតែកាត់ចិត្តលះលាកល្យាណ    គូបូរាណកាលកម្មចាំចាកចរ។

ដល់ពេលផ្គុមលោកជំចុះចាកស្ថាន    ឡើងរថយានទិមសេះដ៏បវរ
សារថីជំនាញទាញបើកបរ    បទចរចុះដល់កំពង់ទឹក។

ពួករាជការបារាំងទាំងខ្មែរយួន    សឹងតែងខ្លួនជូនដំណើរអ៊ឹកធឹក
ពួកទាហ៊ានជើងខ្មៅប្រចាំសឹក    ដង្ហែត្រឹកចុះកប៉ាល់ជាស្រេដា។

នាយតៃកុងទាញខ្សែរស ប្លេកង    លាន់បីដង ម័តឡូស្រាវយិថ្កា
សទិមពេញក៏ចេញចមឧត្តរា    តាមគង្គាហូរត្រង់ដម្រង់ចរ។

តៃកុងយួនបេះក្បួនចង្កូតត្រង់    កាត់ដម្រង់តាមជ្រោយប្រាងសាគរ
ចក្រវិលវាយទឹកពន្លឹកខ្ទរ    អ្នកនគររត់មើលគ្រប់លំនៅ។

កប៉ាល់លឿនដល់គយខ្ញុំគយគន់    យល់តំបន់មេគយប្រចាំផ្លូវ
មានសសរគោមតាំងមុខលំនៅ    មើលៗទៅទីលំនៅមិនសមសក្ដិ។

ផ្ទះរយាកតាករយាលស្បូវរយោង    ភាពជាខ្មែរកែជារោងយោងជាថ្នាក់
ឱគយនេះយ៉ាងជាគ្នាខាត់ប្រាក់    គ្រាន់តែត្រួតមើលអ្នកចូលចេញក្រៅ។

នឹងមានហូតពន់ដាការក៏ទេ    គ្រាន់តែគេចូលប្រាប់ក៏ហួសទៅ
ឱគយនេះឥតពន់ធន់តាំងនៅ    ធ្វើតែស្រូវដាំច្បារចំការស៊ី។

រាជការសៀមតាំងគយនៅចុងស្រុក    ពុំឃើញមានទំនុកឲ្យហូតអ្វី
កោតមេគយនៅចាំជាប្រក្រតី    រាជការថ្មីលោកលើកពុំបំរុង។

ឱអ្នកគយគេធ្វើចំការស្រែ    មិនជួញប្រែយ៉ាងយើងអ្នកស្រុកក្នុង
កោតគេរកធន់ធានគ្មានកោងកុង    ស្ងំផុកផុងដិតកាយក៏ឥតថា។

ស្តាយតែរូបនារីរាងស្រឡៅ ចុះស្លូងស្រូវត្រូវកំដៅព្រះសូរិយា
ជិតទាំងដីផុកផង់ហ្វូងភក្ត្រា អនិច្ចាជាតិអ្នកក្រត្រង់ទៅ។

ប្រសិនមានមាសប្រាក់នឹងសក្តិយស ស៊ីក៍ខ្ពស់ដេកក៏ខ្ពស់ឥតមោះមៅ
បំរុងលាបទឹកអប់នឹងប្រេងម្សៅ កាល់ចាប់ខ្មៅតែងខ្លួនឲ្យនួនល្អង។

តែងប្រកួតអួតឆោមប្រលោមប្រុស ត្រកូលខ្ពស់យល់ហើយមិនកន្លង
នេះមកត្រូវកំដៅផុកផង់ផង នឹងស្គាល់ស្នងចងចិត្តស្និទ្ធម្តេចបាន។

គន់ៗ គិតអាណិតនារីតូច កើតក្នុងពូជហីនយស់ខុសសន្តាន
តោងត្រងនឿយយ៉ាកលំបាកប្រាណ ទម្រាំបានមាសប្រាក់ធ្លាក់ដល់ចាស់។

ចាស់ហើយតើនឹងតែងតួម្តេចល្អ ប្រុសនឹងតថ្លៃទិញយល់ក្រណាស់
ឃើញជាចុះថ្លៃថោកល្មមបោកប្រាស ការសង្វាស់នឹងសង្វាតដាច់សង្វែង។

សម្ពាងទន់ក្រចន់តោងចន់អត់ ក្តីនឿយហត់រកស៊ីតាមដំណែង
គេអ្នកមានគេតែងកាយចិញ្ចែង មិនដូចខ្លួននួនឯងផុកស្រម៉ក។

អង្គុយគន់នារីឲ្យភិសវង់ កប៉ាល់លឿនដល់ចុងអន្សង់សក
ស្ទឹងក៍តូចបទក៍ខ្លីបីបួនច្រក សំណាត់កកដេរដាសពាសពេញស្ទឹង។

នាយតែកុងកាច់ច័ក្រពុះសំណាត់ ច័ក្រក៍កាត់ខ័តណែនកប៉ាល់នឹង
ពួកម៉ាត់ឡចាក់ថ្នោលដោលទទឹង ច័ក្រក៏រឹងផាត់វិលកប៉ាល់រា។

ពួកអ្នកថ្នោលរឹងដោលសំណាត់ញែក កប៉ាល់ជ្រែកវែកច្រានបាន មួយគ្រា
សំណាត់ចុកកប៉ាល់ជាប់ច័ក្រខំពា មើលវេទនាច័ក្ររើសំណាត់រិត។

ខ្ញុំគន់មើលសំណាត់រ៉ាត់កប៉ាល់ ដូចរាគកាល់រូបកាយចុះចារិត
ពុំឲ្យរូបរើរួចពីទីល្ងិត បំបាំងបិទត្រៃលក្ខណ៍បាត់រស្មី។

កាមរាគរោលរិតសត្វក្នុងលោក ឲ្យសត្វនៅសៅសោកក្នុងលោកិយ៍
រាងកប៉ាល់ដូចរូបយើងប្រុសស្រី ប្រាជ្ញាខ្លីមិនយល់កល់ត្រៃលក្ខណ៍។

ស្លាបច័ក្រគឺប័ញ្ញាឆ្ការកប្បណ៍កាត់ កងសំណាត់គឺរាគឲ្យលោកធ្លាក់
បានរួចចេញចាកទុក្ខសោករោគរាក់ អាស្រ័យច័ក្រគឺប័ញ្ញាក្លៀវក្លាហាន។

គ្រឿងកប៉ាល់ដូចកល់អាការយើង ដីទឹកភ្លើងខ្យល់គឺធាតុ ៤ស្ថាន
ចង្កូតគឺសតិរំពៃកបាន ថ្នោលដោលច្រានគឺសមាធិចិត្តដាក់។

សំណាត់គឺបាបធម៍និវរណៈ បិទបាំងកៈមិនឲ្យយល់ត្រៃលក្ខណ៍
ទឹកហូររល់ដូចកល់សង្សារច័ក្រ ឲ្យសត្វធ្លាក់នៅក្នុងអន្លង់កាម។

ឱអនិច្ចារូបកាយមិនណាយលោក អំពីរាគនៅតែរឹងក្រឡឹងតាម
បានជាដល់ទុក្ខមកយំរហាម ព្រោះមិនតាមពុទ្ធកិច្ចភ្លេចស្មារតី។

ខ្ញុំគិតៗ គួរសង្វេករូបអាត្មា មកលុះចុះតណ្ហាការលោកិយ៍
ឃើញធម៍ហើយក៏នៅតែនឹកស្រី ជាចំណីរាគរិតបិទមុខមាត់។

កាច់មិនបានច្រានមិនបែរឹងតែបិទ អាណាចចិត្តអាណិតចៅមកប្រាសព្រាត់
គ្រាន់នឹងតាមព្រះបន្ទូលជាបន្ទាត់ លោកិយ៍អត់កត់មិននឹងទទឹងគាង។

យក ធម៍ព្រះមកលះភ្លើងមិនឈប់ ងងឹតឈឹងដូចយប់មិនយល់រាង
ឱលោកិយ៍លះក្រគ្រាន់តែព្រាង ដូចគេលាងព្រៃខ្មៅត្រូវជ័រទឹក។

ខំដុសលាងយ៉ាងណាមិនឡើងពណ៌ ជាតិជាជ័រជាប់នៅខ្មៅស្រមឹក
ដូចកិលេសជាប់សត្វចាត់ជាសឹក អ្នកកុំនឹកគិតលាងឲ្យជ្រះបាន។

ដូចរូបខ្ញុំខំលះរិតតែរឹង ទប់មិននឹងតាំងមិននៅផ្លូវកម្មដ្ឋាន
អង្គុយគិតយកធម៍ទរមានប្រាណ ដូចគេច្រានសំណាត់សាត់មួយគ្រា។

ដល់ហួសទៅសំណាត់សាត់មកវិញ ប្រមូលពេញដូចដើមណានួនណា
ឱសំណាត់នេះប្រៀបដូចតួតណ្ហា នឹងកាប់ឆ្ការយ៉ាងណាក៏ណែនវិញ។

គន់សំណាក់ សាត់ជាប់ចុងចំការ ទាំងខ្មោចឆ្អែតខ្មោចឆ្អាគ្រាពាសពេញ
ខ្លះរលួយខ្លះប្រែះពោះរៀនចេញ ក្អែកត្មាតដេញគ្នាស៊ីជាភក្សា។

ខ្ញុំគន់មើលសាកសពចំណីក្អែក គិតសង្វេកដល់រូបនៃអាត្មា
ឱសត្វក្អែកមកលុះក្តីមរណា សូល្បីជីវាគេចោលបណ្តែតទឹក។

កាលពីរស់កឹងកាចអំណាចមាន សត្វតិរច្ឆានដូចគ្នាមិនហានចឹក
ដល់ខ្លួនស្លាប់គេអូសបណ្តែតទឹក ក្អែកត្មាតគ្រឹកចឹកស៊ីមិនគ្រាន់ឡើយ។

ឱអនិច្ចាសង្ខារសត្វទាំងឡាយ តែបែកកាយរំលាយខន្ធទៅហើយ
គេក៏កើតខ្ពើមឆ្អើមពុំជិតឡើយ យើងគេអើយគួរគិតផ្លូវអនិច្ចា។

ខ្ញុំបាទខំសង្វេកសាកអសុភ រាគមិនឈប់ចេះតែរោលទាំងរូបា
នឹកតែទៅដល់ពៅកែវសុគា អនិច្ចាថាតែមាត់ចិត្តមិនចាំ។

អសុភ ១០ សម្រាប់លោកលាងលោក កំចាត់រាគចារិតចិត្តបឋម
ព្រះយោគីលោកសមាធិចុះ អារម្មណ៍ ប្លែកតែខ្ញុំពុំចាំអារម្មណ៍ឡើយ។

យកសពឆ្អែមកប្រែនឹងរូបកាយ មិនរសាយណាយសោះណាលោកអើយ
ធ្វើម្តេចហ្ន៎បានលោកឯណាអើយ ជាកោះត្រើយណែផ្លូវឲ្យទានវ៉ា។

មួយសង្ស័យនឹងពាក្យអន្សងសក ពាក្យប្រែបកដូច្នេះគួរសង្កា
សត្វអន្សងវាសកពីកាលណា បានជាមកសញ្ញាឈ្មោះយ៉ាងនេះ។

សត្វអន្សងមិនដែលសកសោះទេ នេះហេតុអ្វីក៏គេហៅដូច្នេះ
ឬគេឃើញសំណកនៅនេះឯះ បានជារិះត្រែះនាមមកឥឡូវ។

រឹងពិនិត្យគិតមិនយល់សែនឆ្ងល់ពេក ការឈ្មោះប្លែកនាមសត្វបាត់មិនត្រូវ
អន្សងសកលោកណាឲ្យនាមហៅ បានជានៅ នាមជាប់ឥឡូវនេះ។

តែបើគិតគួរកោតលោកបូរាណ ចេះគិតអានសន្មតិនាមយាងនេះ
ទីព្រៃសោះចេះឲ្យឈ្មោះច្នោះច្នែះ ពេញជាចេះកម្មតកត់នាមនៅ។

អង្គុយគិតចិត្តភ្លើនរំភើយខ្យល់ កប៉ាល់គ្រឿនលឿនដល់ព្រែកក្របៅ
ទឹកក៏នឹងពុំហូរចុះទៀតទៅ ឃើញទឹកខ្មៅថ្លាយង់ឥតរាគា។

ក៏ដឹងថាជាទឹកទន្លេដល់ ទឹកស្ទឹងកល់ហូរទល់ប្រសប់គ្នា
បានជានឹងពុំហូរត្រឹមណោះណា នឹកសង្កាព្រែកក្របៅហៅសែនឆ្ងល់។

ព្រែកនេះតើបែកមកពីណាឯះ ឃើញតែចុងត្រឹមណេះមិនឃើញគល់
ឬព្រែកនេះទំនាបជាភាពទាល់ គួរពិភ័លចិត្តណាស់ព្រែកក្នុងព្រៃ។

ព្រែកនេះតើគេជីកឬកើតឯង លោកមកតែងនាមក្របៅនៅច្នេះនៃ
ខ្ញុំពីគ្រោះមិនអស់ក្តីសង្ស័យ កប៉ាល់លឿនដល់កន្ត្រៃថ្ងៃក៏ទាប។

ព្រែកកន្ត្រៃកាត់ត្រង់ត្រូវកញ្ចះ ទីស្រឡះគេដើរបានរៀងរាប
ព្រៃដុះល្បោះចុះតាមទីទំនាប អ្នកស្វែងលាភរកត្រីអាស្រ័យបាន។

ព្រែកកញ្ចះទីស្រឡះគេដើរដល់ ស្រុកមង្គល់បូរីជាជ័យថាន
គិតៗទៅគួរកោត លោកបូរាណ ចេះគិតអានចាត់ព្រែកឈ្មោះប្លែកគ្នា។

មួយសង្ស័យនឹងនាមកន្ត្រៃនេះ នរណារិះចាត់ឈ្មោះទុក្ខច្នេះណា
វិស័យទីជាស្ថានព្រៃព្រឹក្សា មកស័ញ្ញាហៅកន្ត្រៃសង្ស័យស៊ុន។

ឬកន្ត្រៃលោកណាធ្លាក់នៅនេះ បានជារិះយកនាមនេះមកគុណ
ឬមានជាងកន្ត្រៃគេនៅមុន ឬអ្នកបុណ្យឲ្យឈ្មោះព្រោះជាប់គ្នា។

រំពឹងគិតមិនយល់ដល់ព្រលប់ ពេលក៏យប់ម៉ោង១ ដល់បាក់ព្រា
តែកុងទាញសះប៉េឡើងបីសា ប្រាប់នាវាឲ្យចៀសកប៉ាល់ចូល។

លុះចូលដល់ស្ពានផែមុខសាលា បោះយុថ្កាចតចងតាមទំនួល
លោកមោនសៀនាយគយចិត្តសោះស្រួល មកទទួលលោកធំទៅត្រីហា។

ចៅភ្នំកងារនាំឧសផ្ទុកកប៉ាល់ ដាក់ពេញទាល់ទាំងល្វែងនៃនាវា
លោកបាល័ត្តចាត់លៀង១វេលា ទាំងអស់គ្នាគេសែនសប្បាយចិត្ត។

តែខ្ញុំ១ ព្រួយប្រាណរំខានសល់ ចង់តែដល់បានយល់ចមបពិត្រ
អស់រាជការនឹងបានវិលស្ថានស្ថិត មិនដឹងគិតកែផ្លូវឲ្យត្រូវឡើយ។

អង្គុយគិតដើរគិតដូចពុលផ្សិត រាគក៏រិតរោលរាលរាមិនស្បើយ
លុះដល់ម៉ោង២ ខ្យល់រំភើយ គ្រាន់លំហើយក្តីទុក្ខពីមុខបាន។

មើលទៅស្ទឹងបាក់ព្រាជាផ្លាធំ ពួកអ្នកឈ្នួញមកជុំទាំងបីដាន
មួយគឺស្ទឹងមង្គល់បូរីស្ថាន ពីរគឺដានព្រះដំបងបីទន្លេ។

ទីស្ទឹងនេះកាលរាជសៀមចាយចែក ចាត់ឲ្យហៅសាមយ៉ែកភាសាគេ
ព្រោះដានបីចេញទៅមាត់ទន្លេ បើតាមគេឃើញត្រូវជាផ្លូវបី។

ឯពាក្យហៅបាក់ព្រាពីបូរាណ គ្មានភិយ៉ានឡាក់ថាននឹងរូបអ្វី
ឬបាក់ព្រាបាក់នេះជាពាក្យថ្មី បូរាណស្ដីថាបាត់កំបិតព្រា។

នរណាបាត់កំបិតនៅនេះឯះ បានជាជាប់នាមនេះដូច្នេះណា
ស័ព្ទកំបិតយល់លើសយាវវាចា មកស័ញ្ញាថាតែបាក់ព្រាវិញ។

ឱបានលោកប្រាជ្ញណានឹងសួរសាក ឲ្យដឹងពាក្យបាក់ព្រានេះឯងមិញ
រំពឹងទៅមិនយល់សល់សែនម្នេញ កាលណាលោកនឹងចេញកប៉ាល់ទៅ។

រំខានទុក្ខនឹងមូសវាយាយី ឯណាទុក្ខនឹងស៊ីម៉ៃមីខៅ
ឯណាទុក្ខនឹងនឹកដល់ឆោមឆៅ ឯណាទុក្ខនឹងក្ដៅចង្អៀតគ្នា។

នឹកទន្ទឹងបានតិចលេចឡូងបុក លាបសសុទ្ធីអុំងបមកម្ទឹម្នា
លោកកុម្ទីសែរក៏ឡើងកាន់នាវា រ៉ុងឲ្យស្រាវយុថ្កាចេញរ៉េៗ។

ខ្ញុំគ្រាន់ស្បើយក្ដីមោះព្រោះចង់ឆាប់ ច័ក្ររើងកប្បូណ៌ទឹកខ្វាតខ្វេរទាំងព្រៃ
កប៉ាល់គ្រឿនលឿនលើជលាល័យ បើកអស់ដៃមើលព្រៃប្រប៉ះគ្នា។

ដល់ត្រៃភពកាច់ប្រែបែឧត្តរ ក៏រើងចរតាមបទទីគង្គា
នឹកសង្ស័យត្រៃភពនេះមុហិមា តាំងនាមាឃើញកើនលើសប្រមាណ។

ពាក្យត្រៃភពប្រារព្ធនាមព្រះពុទ្ធ មិនគួរគេមកចុតឈ្មោះភូមិស្ថាន
ទីនេះសោតពួកនសាទគេរាប់អាន តាំងជាស្ថានបាយ៉ាបចាប់ត្រីទេ។

នេះហេតុអីយកនាមព្រះឲ្យឈ្មោះ មិនគួរសោះនឹងពាក្យអ្នកទន្លេ
នរណាឯះចាត់នាមនេះមុនគេ ឬគេត្មេរព្រោះព្រែកបែកបីភ្លោះ។

សព្វត្រៃភព្វប្រែថាភព្វទាំងបី ព្រះជិនស្រីជាត្រៃភព្វចំពោះ
ព្រោះព្រះអង្គវិសេសគុណពីរោះ បានជាឈ្មោះព្រះចមត្រៃភព្វភារ។

ឯព្រែកនេះពុំឃើញវិសេសអ្វី វិសេសតែនឹងត្រីជាអាហារ
ពុំគួរតាំងនាមស្មើសាស្ដាចារ្យ ឬហៅដោយវោហារអស្ចារ្យក្រៃ។

រំពឹងគិតមិនយល់សព្វត្រៃភព្វ ចង់តែឈប់ទៅមើលទីនោះនៃ
ជាមានអ្វីសាក្សីកណ្ដាលព្រៃ គួរសង្ស័យនឹងពាក្យត្រៃភព្វនេះ។

ឬសព្វត្រៃហៅក្រៃលោកតាំងឈ្មោះ គង់ពីគ្រោះតាមហេតុមានច្នោះច្នេះ
ឬពីដើមព្រះយាងមកនៅនេះ បានជារិះតាំងហៅត្រៃភព្វហោង។

ឱលោកណាដឹងការហេតុដើមដាន សូមមេត្តាប្រោសប្រាណប្រាប់ខ្ញុំផង
ខ្ញុំពីគ្រោះមិនយល់រឹងមួហ្មង កប៉ាល់ឆ្លងកាត់យោគយាងយាវខ្មី។

លឿនលន្លិមតាមបទយាងយាវត្រង់ កាត់ដម្រង់បែត្រង់ដល់ភូមិថ្មី
ភូមិនោះមានគេនៅជាប្រក្រតី បទក៏ខ្លីជាប់នាមពាមសីមា។

ឱស្រុកពាមចាត់នាមឈ្មោះពីរោះ គេប័ញ្ញះសីមាពីកាលណា
ត្រើយខាងជើងមានព្រែកបែកជាស្នា ឮគេថាស្ទឹងនោះទៅទឹកជោរ។

ឱទឹកដោរទឹកហូរពីភ្នំណា ធ្លាក់មកពាមសីមាងាសពេញពោរ
ទឹកទន្លេឡើងកល់ទល់មិនហូរ កាត់ទឹកដោរដល់ព្រាត់វត្តឈើខ្មៅ។

គន់មើលទៅវត្តលោកលើគោកស្រួល ជាទីទួលសមជាអារាមនៅ
ឯវត្តនេះយកនាមឈើមកហៅ នាមឈើខ្មៅលោកណាតាំងនាមនេះ។

ឬវត្តនេះស្រីខ្មៅចៅធ្វើទេ យកនាមគេមកតាំងទុកដូច្នេះ
ឬពីដើមមានឈើខ្មៅនៅនេះ បានជារិះតាំងនាមមកឥឡូវ។

ពាក្យឈើខ្មៅហៅហាក់នាមខ្មៅបង ចិត្តចាប់ចងនឹកដល់កែវឆោមឆ្មៅ
ឱព្រះគុណព្រះកែវវត្តឈើខ្មៅ ខ្ញុំលាទៅនគរវត្តព្រាត់កន្និដ្ឋា។

សូមព្រះគុណប្រោសជួយចក្រពង្ស ឲ្យស្តេចទ្រង់ចំរើនដោយយស្សា
ប្រោសប្រាណខ្ញុំឲ្យបានទីឧកញា កបសក្តារុឌ្ឍីស៊ីសុវត្ថិ៍។

មែនបើខ្ញុំសម្រេចដូចប្រាថ្នា ខ្ញុំនឹងគិតហែផ្កាមកថ្វាយថ្វាត់
សូមកុសលព្រះគុណជួយបំបាត់ សព្វទុក្ខរោគខាត់សកលកាយ។

មួយសូមជ័យជំនះឈ្នះសត្រូវ ទៅតាមផ្លូវកុំឲ្យមានអន្តរាយ
ទាំងពាលម្រឹគយង់ឃ្នងផងទាំងឡាយ ចៀសឲ្យឆ្ងាយដោយអំណាចព្រះចមត្រៃ។

ខ្ញុំសំពះបន់ព្រះវត្តឈើខ្មៅ កប៉ាល់គ្រឿនលឿនទៅតាមជលាស័យ
ត្រូវព្រះពាយរំភើយខ្ញុំនឿយក្រៃ ក៏លក់តាមសម័យយប់នោះឯង។

លុះបើកដល់មាត់ពីរចេញទន្លេ កប៉ាល់រេបើកពុះឆ្លងវាលវែង
វាយុយោគផាត់មករលកផ្សែង ខ្ញុំបាទឯងក៏ក្រោកចាកដំណេក។

អង្គុយគន់មើលទឹកទន្លេសាប ឡើងលិចដាបព្រៃព្រឹក្សពន្លឹកពេក
មើលទៅទិសទក្សិណសែនវិវេក ឃើញតែមេឃមួជិតងងឹតឈឹង។

គន់ទៅទិសឧត្តរតគសាណ ឃើញជាដានព្រៃវង់វែងរងឹង
មើលទៅទិសបស្ចឹមវាលដូចបឹង ទឹកឡើងនឹងពោរពេញមើលល្បោះៗ។

កប៉ាល់រឹងច័ក្រដើរស្មើមិនឈប់ រលកខ្ទប់ស្ទើខ្ទាត់ច័ក្រពាតពុះ
រលកយោលខ្មោលឡើងដូចគេបោះ កប៉ាល់ស្ទុះទឹកបែកញ្ញែកសាចជះ។

វាយុបោកកប៉ាល់បែលលេលឿន រលកគ្រឿនច័ក្រគ្រាន់បើកជំនះ
តែកុងកាច់តាមកៀនរលកជះ កប៉ាល់រះទឹករាយបែកផ្កាត្រែង។

មើលទៅទឹកធំពន្លឹកគួរតែខ្លាច រលាមស្វាចលិចព្រៃមើលបែកផ្សែង
នឹកសង្ស័យទន្លេសាបនេះឯង លោកណាតែងនាមត្រូវទំនងម្លេះ។

ពាក្យហៅថាទន្លេគ្មេមិនដល់ សព្ទនេះយល់មិនត្រូវពាក្យអ្នកចេះ
បាឡីទឹកគ្មានតួ(ទ)ទេឯះ ហៅជលេដូច្នេះទើបបានត្រូវ។

នេះមកហៅទន្លេអក្សរ (ទ) ជាយក (ជ) ជា (ទ)ឬម្តេចកូវ
តួ (ន) ជាវគ្គន្តប្រកបនៅ ស្តាប់ៗទៅមិនត្រូវពាក្យបាឡី។

ឬបូរាណគេហៅជលេទេ ដល់ក្រោយយារពាក្យគេកើតពាក្យថ្មី
ទៅជាហៅទន្លេខុសបាឡី ឬសំដីបូរាណហៅយ៉ាងនេះ។

ឬសព្ទនេះជាពាក្យសង្ស្រ្កឹត លោកប្រសិទ្ធិ៍តួ (ជ) ជា (ទ) ឯះ
ធ្វើម្តេចហ្ន៎បានអ្នកប្រាជ្ញណាចេះ នឹងសាកសួរសព្ទនេះឲ្យច្បាស់រ៉ា។

ឱទន្លេនេះធំមើលបាត់ត្រើយ លោកណាអើយមកសាងយ៉ាងច្នេះណា
ឬក៏កើតពីបឋមក័ល្បា ជាធម្មតាទឹកដីពីបូរាណ។

នឹកៗទៅគួរកោតធម្មតាម្លេះ ចេះរិះឲ្យកើតជាភូមិស្ថាន
ជាទន្លេព្រែកស្ទឹងបឹងបួបាន សម្រាប់ទុកជាស្ថានមច្ឆានៅ។

ទីខាងលើចេះធ្វើជាទួលគោក សម្រាប់លោកអាស្រ័យនៅគតសៅ
តាំងជាភ្នំក្រមថ្មួតទៀតទៅ ជាលំនៅសព្វសត្វម្រឹគប័ក្សី។

ឱធម្មតាចេះចាត់ជាដានៗ សម្រាប់ទុកជាស្ថានយើងលោកិយ៍
លោកណាឯះបង្កើតអស់ទឹកដី តាមបាឡីថាកើតដោយធម្មតា។

តែខាងសាសន៍អារាប់នូវផ្ងាចាម គេស្ដីតាមដំរារៅហារថា
ទឹកដីនេះគឺអង្គព្រះអាឡ្លា យហោវ៉ាគេសាងសម្រាប់លោក។

ខ្ញុំពិគ្រោះមើលតាមគម្ពីរផ្ងា ឃើញខុសគ្នានឹងហេតុទឹកដីគោក
បើអាឡ្លាសាងមែនគួរអផ្សោក ឲ្យត្រូវគ្នាទាំងលោកនោះយល់មែន។

នេះទឹកដីនឹងសព្វសត្វមនុស្សម្នា ឃើញពីរុធខុសគ្នាទៅទាំងផែន
ឯណាល្អក៏ល្អលើសទាំងដែន ឯណាសោសោសែនទាំងភារា។

ដូចដីយើងបាត់ដំបងជាតិដីខ្មៅ ធ្វើស្រែស្រូវកើតផលតែរាល់គ្នា
ស្រុកសៀមរាបម្ដេចដីខ្សាច់មុហិមា ធ្វើចំការស្រែស្រូវមិនសូវផល។

មួយគឺខាងយូរុបម្ដេចចាត់ល្អ មនុស្សក៏សច្រើនធំទាំងសាកល
ខាងតណ្ដៀមនុស្សខ្មៅៗពិកល ខាងមណ្ឌលយើងម្ដេចមនុស្សតូចទាប។

មួយព្រឹក្សាលតានាមដូចគ្នា រសឱជាម្ដេចខុសគ្នារៀងរាប
ទាំងសត្វសោតក៏ខុសអត្តភាព ខ្លះក៏ទាបខ្លះក៏ខ្ពស់ឃើញខុសគ្នា។

បើអាឡ្លាសាងមែងម្ដេចដូច្នោះ ខ្ញុំពីគ្រោះមិនសមនឹងផ្ងាថា
វិស័យព្រះនោះប្រៀបដូចបិតា គោងមេត្តាដល់បុត្រស្មើព្រះទ័យ។

នេះមកសាងឲ្យកូនមិនស្មើមុខ ជាអាពុកមនុស្សឬខុសនិស្ស័យ
ស្ដាប់ទៅយល់មិនត្រូវអផ្សាស្រ័យ ទឹកដីព្រៃក៏កើតដោយធម្មតា។

ដូចយ៉ាងទឹកទន្លេនឹងសមុទ្រ ឃើញធំផុតទូលាយឆ្ងាយណាស្សា
ពួកអ្នកឈ្មួញដើរជួញរកភោគ្គា សឹងសែនមហាលំបាកដោយព្យុះខ្យល់។

ឬអាឡ្លាឥច្ឆាពួកអ្នកឈ្មួញ មិនឲ្យគ្នាដើរជួញក្រោមណ្ឌល់
បានជាមកបង្កើតជាព្យុះខ្យល់ ឲ្យលិចលង់ទូកទល់ទាល់វេទនា។

អើបើយ៉ាងខ្មែរយើងមិនចូលសាសន៍ គួរធ្វើផ្ដាស់ទៅចុះក៏ឥតថា
ចុះពួកផ្ងាដែលគ្នាខំឧស្សាហ៍ ប្រដិបត្តិសព្វគ្រាតាមមហាម៉ាត់។

ឯណាយប់គ្នាបួសកាន់ខន្តី ថ្ងៃឡើងឆ្លៀតបង់ត្រីសំលែះសត្វ
ឯណាគ្នាហ៊ានឲ្យតុកតួនកាត់ ខំប្រដិបត្តិមហាម៉ាត់មិនឲ្យឆ្គង។

គួរឬអាល័សឡើមិនប្រោសប្រាណ មកក្លែងធ្វើជលថានធំកន្លង
គ្នានាំព្រៃទៅលក់ស្រុកបាត់ដំបង ឲ្យគ្នាហ្វងឆ្លងទៅត្រូវព្យុះខ្យល់។

បើយើងជាអាល័សឡើមិនធ្វើច្នេះ ទីត្រង់ណេះគួរធ្វើឲ្យកើតថ្នល់
ឲ្យអ្នកទូកដើរស្រួលមិនគោងល្វល់ នឹងព្យុះខ្យល់ដូចយ៉ាងអាឡ្លាសាង។

ទីត្រង់ណុះគួរសាងជាកោះធំ ឲ្យភិរម្យមនុស្សនៅទាំងសងខាង
តាំងក្បាលកោះឲ្យកើតជាព្រះប្រាង្គណ៍ មានមាត់បាងចូលចេញឲ្យសប្បាយ។

នេះអាឡ្លាមកសាងទន្លេសាប ដាលតែទឹកទៅរាបទូលាយឆ្ងាយ
មនុស្សទៅមកសែនយ៉ាកលំបាកកាយ ព្រោះអន្តរាយដោយខ្យល់តែរាល់គ្នា។

អើពួកផ្ងាគេថាព្រះគេសាង នឹងឯបអាងមិនសមនឹងកិរិយា
ពាក្យនេះអញ្ជើញពិចារណា ជាយកខាងធម្មតាឬអស់លោក។

ឬយកខាងព្រះអាឡ្លាដែល ថានោះ សូមពិគ្រោះមើលចុះតាមអផ្សោក
ឯទឹកដីថ្ងៃខែសម្រាប់លោក គួរប្រយោគមើលហេតុមើលកិរិយា។

កប៉ាល់ដើរលុះដល់ចុងភ្លៀសថ្វាត់ តែកុងចាត់ចូលចតបោះយុថ្កា
នាំគ្នាដេកសម្រានតាមធម្មតា អនិច្ចាតែខ្ញុំពុំលក់ឡើយ។

ពុលរលកក្អករលើកនឹកដល់ផ្ទះ កត់មិនឈ្នះគេមិននឹងព្រលឹងអើយ
ត្រូវមកដេកកប៉ាល់ខ្យល់ល្ហើយៗ ផាត់រំភើយរលកបោកផាៗ។

គន់ទៅខាងឃើញសើនគោមពីរភ្លោះ    ភ្លើងភ្លឺប្រោះប្លុងៗក្នុងគង្គា
គោមពីរនោះឆេះនៅសព្វវេលា    តាំងជាផ្លាប្រាប់ទ្វារស្រុកសៀមរាប។

ខាងមាត់ពីរក៏តាំងគោមឆ្វេងស្តាំ    អុចប្រចាំចូលចេញទន្លេសាប
ខ្ញុំគន់ៗនឹកកោតលោកដរាប    មកលះបាបលោភបុណ្យចេញធន់ធាន។

ទិញប្រេងអុចគ្រប់ដានពាមទន្លេ    ទុកឲ្យគេអ្នកដើរក្នុងជលថាន
ដល់ពេលយប់នឹងដឹងទីដែនដាន    ចេញចូលបានឥតមានក្តីថែងវែង។

គោមនោះសោតចេះនៅជាប្រក្រតី    ដល់រាត្រីទើបឃើញភ្លើងភ្លឺទែង
ដល់ពេលថ្ងៃពុំយល់ព្រោះសុរ្យសែង    គេចាក់ថែងថែមប្រេង ១០ ថ្ងៃម្តង។

ខ្ញុំយល់ ៗ សរសើរលោកបារាំង    លោកមកតាំងអុចគោមភ្លឺកន្លង
ប្រាថ្នាទុកជាទានឲ្យអ្នកផង    បានដើរឆ្លងឃើញភ្លើងជាសញ្ញា។

ឱស្រុកខ្មែរតាំងតែពីនេះទៅ    មានតែសុខឥតសៅឥតទុក្ខា
បានបារាំងលោកតាំងគ្រងរក្សា    តែងសីមាកម្ពុជាឲ្យពណ្ណរាយ។

តែត្រឹមទីទន្លេជាស្ថានស្ងាត់    មកចេះចាត់អុចភ្លើងប្រចាំហ្វាយ
រាស្ត្រទៅមករកស៊ីតាមស្រុកឆ្ងាយ    ដើរសប្បាយមិនគោងវង្វេងផ្លូវ។

ឱទន្លេតាំងតែពីបូរាណ    មិនដែលមាននរណាបំភ្លឺថៅ
ឥឡូវនេះមកបានបារាំងនៅ    ឲ្យអុចគោមទួទៅទាំងគង្គា។

សែនរុងរឿងថ្កើងហើយទន្លេសាប    ពីនេះទៅដរាបឥតភ័យា
ឱរាត្រីយប់នេះជួនវេលា    ខ្ញុំនិទ្រាពុំលក់ជាទុក្ខក្រៃ។

បែទៅទិសបូព៌ាឃើញរស្មី    ព្រះរង្សីអារុណរះសែងថ្ងៃ
ពួកកប៉ាល់ក៏ភ្ញាក់ឡើងទីទៃ    ស្រាវយុថ្កាវៃៗថយម្នីម្នា។

កប៉ាល់គ្រឿនលឿនចូលទៅតាមព្រែក    ណាចង្អៀតក៏ជ្រែកបែកជាផ្លា
តែកុងកាច់បទតាមទីគង្គា    មើលព្រឹក្សាដុះហែតាមក្បែរផ្លូវ។

ខ្លះដើមខ្ពស់លូតលាស់ខ្មែងលំពង់    ខ្លះទាបទឹកលិចចុងឃើញខ្មៅៗ
កោតហ្នំឈើរនាមជន់ណាស់ទៅ    ទឹកលិចនៅ៥ខែប្រែមិនក្ស័យ។

ឱព្រៃអើយព្រៃដុះជារនាម    ខ្លះជារាមស្បាតជិតបិទសែងថ្ងៃ
ខ្លះខ្ពស់ស្រោងផុតទឹកពន្លឹកក្រៃ    សត្វអាស្រ័យជាស្ថានសម្រាននៅ។

កប៉ាល់បើកលុះដល់គន្ធាយគម    ឃើញភ្នំក្រោមនៅខាងឯលិចផ្លូវ
ឱភ្នំក្រោមតូចល្អមមានមនុស្សនៅ    មើលៗទៅពុំឃើញមានដើមឈើ។

ជាភ្នំដិលត្រងិលមានតែស្មៅ    មានដើមពោធិ៍១នៅកំពូលលើ
ក្រោយពោធិ៍មានវិហារគេទើបធ្វើ    វត្តនោះតើលោកណាសទ្ធាសាង។

ឯក្រោយផ្លាវិហារមានប្រាសាទ    វិចិត្រស្អាតដោយថ្មកជាប្រាង្គណ៍
ជារបស់បូរាណលោកសំអាង    ទំនងយ៉ាងបញ្ចុះព្រះធាតុក្សត្រា។

ឬជាទីដំកល់ព្រះបដិមា    សម្រាប់អ្នកសាស្នាឡើងប្រដិបត្តិ
ឱប្រាង្គណ៍នេះលោកណាមកថែងចាត់    មាននៅស្ថានចង្វាត់ខឿនខ្វាត់ខ្វែង។

ឥឡូវនេះជំរុតទ្រុតទ្រោមធ្លាយ    ថ្មរុសរាយតាមជាយជើងកំផែង
ស្តាយអើយស្តាយប្រាសាទប្រសើរស្តែង    បានលោកណាចាត់ថែងជួសជាថ្មី។

មើលប្រាសាទលើភ្នំស្ទើយំស្តាយ    មិនគួរមកអន្តរាយខ្ចាយដោយដី
ស្តាយតែស្នាដៃធ្វើស្ទើកោសី    មិនគួរបីបែកបាក់ធ្លាក់ធ្លាយធ្លុះ។

ខាងជើងភ្នំមានវត្តលោកសង្ឃនៅ    មានផ្លាផ្លូវឡើងទៅខាងវត្តនោះ
ឱភ្នំនេះស្តាប់ទៅយល់ពិរោះ    ស័ញ្ញាឈ្មោះភ្នំក្រោមល្អមមានអាង។

ព្រោះភ្នំគេសឹងតែនៅខាងលើ    មានដើមឈើដុះលើឃើញច្រូងច្រាង
ភ្នំមួយនេះមកតាំងនៅក្នុងបាង    មានទីអាងយ៉ាងនេះជាសាក្សី។

បានជាហៅភ្នំក្រោមព្រោះក្រោមគេ　　នៅខាងជាយទន្លេអ្នកធ្វើត្រី
ឥឡូវមានអ្នកស្រុកនៅប្រក្រតី　　ដាំឫស្សីដូងស្លាចម្ការចេក។

ឱភ្នំនេះជាទីពីបូរាណ　　សមជាស្ថានសំណាក់អ្នកវិវេក
នឹកសរសើរប្រាសាទប្រសើរពេក　　ខ្ញុំក្រឡេកមើលទៅទីឧត្តរា។

ឃើញទីនាំងតាំងចតនៅរៀងរាយ　　ប្រចាំទ្វីបម្ករក្លាយកសាយណា
ទូកគែហៅវើតមួងភាពផាយម៉ា　　ក៏ដឹងថាព្រះទីនាំងព្រះចក្រី។

ចៅភ្នាក់ងារត្រួតត្រាព្រះទីនាំង　　ឲ្យចតតាំងតាមថែវចុងព្រែកថ្មី
ទូករាជវង្សចតក្នុងទូកកុង្សីយ　　ក្រុមមន្ត្រីចតអមលោមក្រៅផ្លា។

ទូកអស់នេះទ្រង់ឲ្យមកប្រចាំ　　មុនទម្រាំព្រះបរមរាជា
ដល់១០កើតថ្ងៃសុក្រស្តេចលីលា　　យាងដោយរាជនាវាកប៉ាល់ធំ។

លុះកប៉ាល់រាជការស្រុកព្រះដំបង　　ទៅដល់ដងវាលវែងជាចុងភុម
លោកឲ្យបោះយុថ្កាចតប្រជុំ　　អ្នកជំនុំនាំគ្នាមើលត្រៀបត្រា។

លុះកប៉ាល់ចតស្រេចលេចទូកបី　　ក្រុមមន្ត្រីសៀមរាបទីឲកញ្ញា
មកទទួលលោកធំជាឥស្សរា　　ថិគេបកភាសាថែងការផង។

លោកកុម្មិសែរអធ្យាស្រ័យតាមហេតុ　　ចាត់ឲ្យលោកចៅហ្វាយខែត្រព្រះដំបង
នៅកប៉ាល់ឯក្រោយចាំរាប់រង　　ទទួលអង្គច្បាស់ច្បងស្តេចយាត្រា។

តែខ្លួនលោកនឹងលោកសង្ឃបិអង្គ　　ពុំរារង់ចុះទូកអ្នកឲកញ្ញា
ខ្ញុំបាទឯងជាបាវលោកមេត្តា　　ឲ្យយាត្រាទៅមុនដោយកំសាន។

ទើបជញ្ជូនហិបពួកដាក់ទូកស្រេច　　មួយរំពេចក៏ចេញតាមជលស្ថាន
ពួកកំណែនកែនថែវខំថែវប្រាន　　កាត់ត្រង់ដានទីជ្រនឹកព្រែកជីកថ្មី។

ថែវឯបរ៉បអបខាងព្រះទីនាំង　　ខ្ញុំក៏តាំងលួចគន់មើលស្រីៗ
ពួកអ្នកក្នុងតែងអង្គល្អប្រិមប្រិយ៍　　ឆវីភ័ក្ត្រហាក់ស្រីទេព្វកញ្ញា។

សឹងប្រដាប់សង្វាចាខ្សែដៃ　　ទំហ៊ំឆ្នៃវិចិត្រវ៉ែចនា
ទាទិមពេជ្រលេចសែងព្រះសុរិយា　　សុកានកែវកាញ្ចណាប៉ព្រាតព្រាយ។

ស្លៀកខៀនខាត់រែតអេរខាំម៉ាសុី　　ផាត់ឆវីគន្ធរស់ពិគោរសាយ
ខ្លះតែងតួសុភាពភាពសៀមក្លាយ　　ខ្លះតែងកាយអារសាយក្លាយបារាំង។

ពួកសាវឡឹកង្គុតទឹកប្រឡែងគ្នា　　សើចហេហាហែលខាងព្រះទីនាំង
ខ្លះមិនខ្លាចអំណាចពួកក្រុមវាំង　　ក៏សើចខ្លាំងលើសគេរតែខ្លួន។

ខ្លះអង្គុយស៊ីយសក់កញ្ចក់ខាង　　ខ្លះសំអាងសមស័ក្តិ៍ហាក់និមន្ទូន
តែងប្រក្ួតអួតអង្គទ្រង់ដោយខ្លួន　　មើលសមសួនសមស័ក្តិ៍ព្រះចក្រា។

ខ្ញុំគន់ៗ សរសើរព្រះបារមី　　ព្រះចក្រីជាថ្ន្បូងលើកេសា
កបនារីស្អាតៗ បាទបរិចា　　សែនមហាចំរើណព្រះកិត្តិយស់។

គន់ទៅទូកពួកសេវកាមាត្យ　　សឹងស្អាតៗ រុងរឿងដោយគ្រឿងខ្ពស់
តែងប្រក្ួតអួតគ្នាតាមស័ក្តិ៍យស់　　បំរុងតាមកាមរសរេណីក្ស័ត្រា។

សរសើរទូកខុននាងនូវនាងអ្នក　　ខ្ញុំតែងដាក់និរាសនេះខាត់ៗ
ពុំពិស្តារវិត្ថារឲ្យច្រើនអត្ថ　　ព្រោះក្តីខាត់ពុំស្គាល់អ្នកភ្នំពេញ។

បានជាតែងសង្ខេបបែបខ្លីៗ　　តាមសេចក្តីយល់ខ្លះមិនច្បាស់មិញ
បើខ្ញុំស្គាល់ឈ្មោះលោកអ្នកភ្នំពេញ　　នឹងតែងចេញឈ្មោះលោកឲ្យគ្រប់គ្នា។

សូមទានទោសកុំខឹងខ្ញុំអ្នកតែង　　មិនសម្តែងឈ្មោះលោកចូលផងណា
ដ្បិតខ្ញុំអ្នកព្រះដំបងក្រៅសេមា　　ហេតុដូច្នោះបានជាតែងកាត់ខ្លី។

ពកកំណែនថែវស្រូតតាមព្រែកជីក　　សែនវិវេកមើលព្រែកគេជីកថ្មី
ទឹកក៏រាក់ហូរចាក់ធ្លាក់អាចម៍ដី　　ថែវទៅដល់ភូមិថ្មីឬសីលក។

ឃើញអ្នកស្រុកតែងផ្កាមាកាល័យ ដោតទង់ជ័យរាយរៀងតាមមាត់ច្រក
ខ្លះតែគូប្រទ្ទាប៉ាប្រដាប់ដក បោះកំប៉ងពែងចកអុចសំអាង។

គន់អ្នកស្រុកសៀមរាបសូភាពគួរ នៅជាជួរដងស្ទឹងទាំងសង្ខាង
ស្ទឹងក៏តូចច្រាំងក៏ទាបជាភាពបាង ទទឹងយ៉ាងបីព្យាមប្លាយប្រាកដ។

រយៈផ្លូវទៅពីចុងភ្នៀសឯង ដល់កំផែងសៀមរាបលោកកំណត់
បានបីរយកៅសិបប្រាំសិនគត់ លោកវាស់ទុកជាបទបែបលាយថែង។

តែខ្ញុំចេញចាកទឹកន្ទាយគម ថ្ងៃទៀបត្រង់ក៏លួមដល់កំផែង
ចែវចូលចតឯបស្ពានភ្នាក់ងារតែង ត្រង់កន្លែងសានខ្វែងត្រើយខាងលិច។

ពួកបាវបោយកូនក្មួយជួយគ្នារើ ទ្រព្យរបស់ដាក់លើគោករំពេច
ខ្លះក៏មានតែទៃនឹងបង្វិច ក៏ស្កាយគេចឡើងគោកជ្រកគ្រឹហា។

បោយបារាំងតាំងរៀបគ្រឿងលើគោក ចាំមើលលោកនៅទីខាងផ្លូវថ្លា
រង់រទេះកំណែននឹងលីលា ឡើងទៅនាប្រាសាទនគរវត្ត។

លោកឲកញាស្មៀនត្រាសទ្ធាបុណ្យ មកនិមន្តលោកសង្ឃទៅផ្ទះគាត់
ចាត់ចង្ហាន់ប្រគេនតាមកិច្ចវត សំរេចភត្តនៅផ្ទះលោកស្មៀនត្រា។

ឯខ្ញុំបាទនាំភឿនទៅផ្សាត្រី ទិញចំណីអាស្រ័យតាមធម្មតា
សុំរេចកិច្ចនាំគ្នាចរយាត្រា មកចាំលោកនៅនាមុខកំផែង។

គន់មើលគ្រឹហស្ថានចៅហ្វាយស្រុក សែនជាសុខសមសក្តិហាក់គួរស្វែង
តាំងគ្រឹហានៅនាក្រៅកំផែង រៀបចាត់ចែងតែងការទទួលស្តេច។

ដោតទង់ជ័យបីជាន់ជាជួរជុំ ប្រកបគុំបុប្ផាផ្ការំលេច
កែមស្លឹកឈើធ្វើស៊ុមប្រទូពេជ្រ រៀបជាក្បាច់វីរវាន់ពាន់ពែនពាក់។

មោនសៀររកស៊ីប៉ាល់បារាំងសែស នាយប្រទេសចាត់ការទាហ៊ានស័ក្តិ
យកកំផែងសៀមរាបជាសំណាក់ តាំងពិភ័ករក្សាការសត្រូវ។

ខ្ញុំគន់មើលកំផែងវែងរឹង ស្វាត់ត្រឈឹងពុំមាននរណានៅ
ព្រៃដុះដិតស្បាតជិតទាំងក្នុងក្រៅ សែនហ្មងសៅ មើលទៅគួរតែស្តាយ។

ប៉មជម្រុតទ្វារទ្រុតធ្លាក់ទីទៃ ពួរពោធិ៍ជ្រៃជ្រៀតចាក់បាក់ធ្លុះធ្លាយ
លោកបារាំងតាំងឲ្យរើទំលាយ យកទៅវាយបំបាក់ចាក់ផ្លូវថ្លា។

ឱកំផែងគេតែងដោយថ្មក្រៀម ស្នាដៃសៀមគេធ្វើកាលយុទ្ធនា
ស្រុកខ្មែរយើងនឹងយួនកើតច្បាំងគ្នា សៀមធានារ៉ាប់រងសង្គ្រាមយួន។

លោកចៅយុនបឱននាយបង្គាប់ ជាមេទ័ពលើកចេញមកតាមក្បួន
ទើបឲ្យកកំផែងប៉មមាំមួន ចាត់ជាក្បួនបន្ទាយការសត្រូវ។

តាំងមកដល់រាជលោកអង្គរយ៉ែម លោកសមសែមចាត់ចែងតែងតាំងនៅ
កាលណោះឯងកំផែងសុខឥតសៅ ដល់ឥឡូវត្រូវដៃរាជការថ្មី។

លោកឲ្យរើទៅវាយដាក់ផ្លូវថ្លា សម្រាប់ឲ្យមនុស្សម្នាដើរប្រក្រតី
ខ្ញុំគិតៗអនិច្ចំទាំងបូរី តែទឹកដីគង់ដល់ផ្លូវអនិច្ចា។

ឱស្រុកសៀមរាបជាភាពចាស់ សឹងខ្សាច់ដាសមិនថាទីត្រង់ណា
អ្នកនឹងរកប្រយោជន៍ស្រែចំការ នឹងបានផលប៉ុណ្ណារក្សាកាយ។

មួយសង្ស័យនឹងស្រុកសៀមរាបនេះ បូរាណរិះឲ្យឈ្មោះខុសបរិយាយ
ស្រុកខ្មែរទេម្តេចគេយកសៀមលាយ តាមបរិយាយសាវតារដំរ៉ាមាន។

កាលព្រះចមចក្រីត្រីនេត្រក្សត្រ គ្រងសម្បត្តិឥន្ទប័តបូរីស្ថាន
គឺនគរធំនៅជាប្រធាន ចមក្ស័ត្រក្សាន្តមានបុណ្យលើសនានា។

មានព្រះនេត្របីភ្នែកប្លែកជាងជន នេត្រកណ្តាលតែគន់មើលនរណា
អ្នកនោះឯងក៏ដល់ក្ស័យជីវា ពួកភារាក៏ស្វែងក្រែងបារមី។

លុះណោងស្នោគឺសៀមជាសួយទឹក កជាសឹកលើកមកវាយបូរី
ដល់មកទីត្រង់នេះបោះយោធី តាំងជាទីសមរភូមិជ័យ។

គ្រាន់ជ្រាបដល់ព្រះនរិន្ទ្រពិនក្រស័ត ចមតន្ទប័តក៏ទ្រង់ព្រះក្រោធក្រៃ
ទើបលើកពួកចតុរង្គក្នុងរៀងជ័យ ចេញតដៃពៃរីរិទ្ធីហាន។

មកដល់ស្រេចស្ដេចបើកព្រះនេត្រកែវ តែមួយប្លែវត្រូវសៀមស្ងៀមមិនបាន
ចោលអាវុធចាក់ដៃលុតក្រាបក្រាន រាបពុំហានតរិទ្ធីរត់វិញទៅ។

ហេតុដូច្នោះបានហៅថាសៀមរាប ព្រោះមានភាពសៀមខ្លាចព្រះចមចៅ
បូរាណរាជចារិកតាំងនាមនៅ ដល់ឥឡូវសៀមប្រែហៅសៀមរ៉ាត។

ពាក្យសៀមរ៉ាតប្រែថាសៀមឥតក្រែង តាំងសំដែងឥទ្ធិរឹទ្ធិ៍គិតប្រមាទ
ដើរទន្រ្ទានរានរុកសីហនាទ មិនក្រែងជាតិកម្ពុជាវេលានោះ។

ព្រោះស្រុកនេះជាស្រុកឡើងសយ៉ាម សៀមធ្វើតាមអំណាចឥតខ្លាចសោះ
ពាក្យ “រ៉ាត” សព្ទនេះប្រែដូច្នោះ បើ រាដ្ឋ វិញនោះថាដែនស្រុក។

ទំនងយ៉ាងសៀមប្រើ ដ្ឋ ជាខ្យល់ ប្រយោគដល់ត្អួ ត តាំងជាមុខ
ខ្ញុំពីគ្រោះសព្ទរ៉ាតឧបាតទុក ឥឡូវស្រុកបានមកខ្មែរវិញហើយ។

គឺបានដោយអំណាចរាជនិវេស ក្រុងបារិសយើងតាំងជាកោះកើយ
សៀមបាងកកលូកមកមិនបានឡើយ យើងបង្ហើយសៀមរ៉ាតហៅសៀមរត់។

ព្រោះកាលសៀមប្រគល់ទឹកដីឲ្យ ត្រឡប់ក្រោយវិលទៅបាងកកហ្មត់
ហេតុនោះគួរពួកយើងបោះប្រាកដ សន្មតគឺហៅស្រុកសៀមរត់វិញ។

ពណ៌នាសៀមរាបគាប សៀមរ៉ាត សែនអានាថនឹកឡើងគួរតែម្ញេញ
ព្រោះពីដើមចុះយួនជួនសៀមវិញ ឥឡូវពេញដូចមុនគុណបារិស។

អើស្រុកខ្មែរកែមុខបានសុខសាន្ត ព្រោះរួមស្ថានភ្នំពេញរាជនិវេស
កិត្តិយយស់សុះសាយទួប្រទេស បារាំងសែសវិសេសជាបិតា។

មួយដូចយ៉ាងប្រាសាទនគរវត្ត បូរាណក្ស័ត្រចាត់សាងក្នុងសេមា
យូរអង្វែងពុំថែងជារាជណា ទៅជាព្រៃព្រឹក្សាស្វាវានៅ។

ពុំមានលោកឯណាជួសជុលបាន ចោលជាស្ថានសមសានសែនហ្មងសៅ
ដល់ឥឡូវបានលោកបារាំងនៅ លោកចាត់ផ្លូវជួសជុលវិបុល្លា។

ពណ៌នាបានតិចលេចរនេះ ព្រមទាំងសែះជុំនីសលោកឥស្សរា
បរមកដល់រចល់ចូលម្ទីម្ទា ខ្ញុំនាំគ្នាផ្ទុករបស់ហើយបរទៅ។

លោកកុម្មីសែរជិះសែះបរទៅមុខ ពួកអ្នកស្រុកនាំគ្នាមើលខ្ជួលខ្មៅ
ពួកខ្ញុំបាទដើរយុំរទេះទៅ ចរតាមផ្លូវខ្សែលួសលោកជួសថ្មី។

ព្រះទិនករចរបែអារុណរែង កំដៅសែងព្រះអាទិត្យ៍រិទ្ធីរង្សី
ពួកអ្នកដើរសែនក្ដៅសៅឆវី ញ៉រឥន្រ្ទិយញើសស្រាក់ប្រឡាក់កាយ។

អនិច្ចាតែខ្ញុំគ្មានឆ័ត្របាំង ត្រូវកំឡាំងព្រះអាទិត្យ៍វិតក្រហាយ
ឯណាទុកនឹងដឹកដល់ឆោមឆាយ សេចក្ដីហ្មាយឆ្ងាយមាសនិរាសមក។

ស្ដាយអើយស្ដាយកាយកែវកន្និដ្ឋា មកផងរ៉ានឹងនាំមើលច្រកល្ហក
ឱដើមរោគដូចរោគរាគវិតរក ចៅដើមធ្លកមិនធ្លាប់មកឯកា។

គន់ព្រឹក្សាលតាដុះដោយព្រៃ ខ្លះលូតលៃលំពង់ទ្រង់ផ្លែផ្កា
សកុណ្ណជាតិហើរចាប់ចុងសាខា ចឹកផលាសព្ទស៊ានអាណែកក្រៃ។

ភ្ញមរីហើរត្រង់កន្លង់ចរ ត្រេបកេសរបុប្ផាពនាល័យ
សព្ទហ៊ឹងៗ ទ្រហឹងកណ្ដាលព្រៃ ច្រទ្បំសព្ទរោរ៉ៃបន្លឺសៀង។

សែនស្រណោះសព្ទសេកវិវេកចិត្ត ទំប្រជិតសាលិកាជាគូគៀង
កោកីលោលោតលេងទំររៀង ប័ញ្ចេញសៀងភូរាំងក្រាំងក្រអៅ។

គន់ចំបក់ដូចបងចំបែងចិត្ត ចៅដើមខ្ចិតដូចបងមកខ្វែងចៅ
ឱដើមសោកដូចបងមកសោកសៅ ដើមស្រឡៅនៅស្រឡាញ់ចេញចោលមក។

ឱដើមថ្លាញ់គេធ្លាប់លាបដំបៅ ដើមស្រឡៅធ្វើថែវគួរកប្បូណ៍យក
ធ្លកអើយធ្លកមិនធ្លាក់ផ្លេចុះមក ខ្ញុំនឹងយកធ្វើប៉ុយបង្គួយពោះ។

គន់ដើមយាងរាង យោរយោកដោយខ្យល់ គេកប្បូណ៍ដុតយកជ័រធ្វើចន្លុះ
អនិច្ចាដើមយាងម្ដេចយ៉ាងនោះ ឲ្យគេចោះទាំងស្រស់ដុតដូច្នេះ។

យាងអើយយាងចៅសាងកម្មយ៉ាងណា បានជាមកវេទនាឲ្យភ្លើងឆែះ
ឈើឯទៀតមិនដូចឈើយាងនេះ បើតាមរិះឈើនេះចុះតំរា។

សមណៈមានទ្រព្យសិកាក្លួន ស្រីមានខ្លួនប្រុសក្លួនដោយកាមា
ព្រឹក្សាជាតិយ៉ាប់យ៉ឺនព្រោះផ្លែផ្កា ត្រីអាំងមានទើបឆ្មាមកយាយី។

យាងឯងយ៉ាប់ព្រោះមានជ័រទឹកនៅ បានជាត្រូវកំដៅព្រះអគ្គី
ឈើឯទៀតឥតជ័រគេរុំខ្លី គ្មាននរណាយាយីដូចយាងឯង។

ឱព្រឹក្សាត្រូវការមិនថាអ្វី កើតសម្រាប់ផែនដីប្រាកដស្ដែង
ដូចរូបកាយសង្ខារគេតុបតែង មិនផុតការគ្នាឯងតែងអាស្រ័យ។

ឱព្រឹក្សាលតានាមប្លែកៗ បូរាណចែកចេះឲ្យឈ្មោះទីទៃ
កោតហ្នុំលោកបូរាណចេះកែខៃ ឲ្យនាមសព្វឈើព្រៃគ្រាន់កំណត់។

រយៈផ្លូវទៅពីសៀមរាបឯង ដល់កន្លែងមុខនាគនគរវត្ត
បាន១៤០សិនទៀងទាត់ សេស៥សិនសន្មមតិកត់មាត្រា។

លុះដើរដល់ជ្រៃធំត្រសុមម្លប បបួលគ្នាចូលឈប់ម្លប់សាខា
សម្រាកញើសរំហើយដោយវាតា ព្រះសុរិយាជ្រេសែងឧនោទ័យ។

ទើបនាំគ្នាចរលីចាកទីនោះ ភ័ក្ត្រាឆ្ពោះដម្រង់ត្រង់ដល់ព្វ
មន្ទីរថ្មីលោកតាំងជារាំងជ័យ សម្រាប់ទីក្សត្រថ្លៃព្រះទ្រង់ស័ក្តិ។

លោកស័ក្តិបីស្ដីទីព្រះអាជ្ញា ជាឥស្សរាក្នុងការព្រះដំណាក់
ចៅហ្វាយខែត្រសៀមរាបបំរុងស័ក្តិ ទទួលភ្ន័កងារកេណ្ឌរាស្ត្រតែងផ្លូវ។

ចៅហ្វាយខែត្រព្រះដំបងរ៉ាប់សំអាង កេណ្ឌពួកជាងរច័នាការក្នុងក្រៅ
ចៅហ្វាយស្រុកគ្រប់ខែត្រគ្រប់លំនៅ សឹងចុះត្រូវកំណែនការទីទៃ។

គឺឲកញាស្វាយចេកចំណែកមុខ នឹងឲកញាភ្នំស្រុកខែត្រជើងព្រៃ
រួមឲកញាសូរ្យសក្ដីសោភណក្រៃ ត្រូវធ្វើព្រះពន្លាជ័យដំណាក់ធំ។

កែណ្ឌឲកញាក្រឡាញ់បញ្ជូលមុខ រួមឲកញាខែត្រស្រុកសូទ្រនិគម
ត្រូវរោងខោលរោងសែកចែកតាមមុម ឯរោងថែវអមជុំត្រូវកំជាញី។

គឺស្រុកពួកស្រុកមោងស្រុកត្នោតផង ទាំងទឹកជោរបាត់ដំបងមង្គលបូរី
ឯឲកញាមង្គលធរនិន្ទថ្មី ត្រូវបើកត្រីអង្ករចែកគ្រប់កង។

ចៅហ្វាយខែត្រសៀមរាបនាយកំណែន ឲ្យកោះកែណ្ឌរទេះជាងរយហោង
កែណ្ឌទូកធំ ៥០ មាននាយកង ចាំរាប់រងចូលចេញខាងជើងទឹក។

កែណ្ឌគូលី ១០០ប្រចាំនៅ តែការដល់គេហៅចុះថែវត្រឹក
រាស្ត្រសៀមរាបរវល់ខ្វល់ពន្លឹក ទាំងជើងគោកជើងទឹកចេញគ្រប់ដាន។

ខាងការល្ហាស់កែណ្ឌសែះ ៥០ ប្លាយ សម្រាប់នាយៗដើរពុំបាន
ទាំងរថាសារថីព្រះរាជយាន ប្រចាំរ៉ាប់ក្សត្រក្សាន្តស្ដេចយាងដល់។

ពួកក្រុម្ការចាត់ការព្រះពន្លា សឹងប្រក្ចតអួតគ្នាគ្រប់មណ្ឌល់
ជ្រើសតែជាងស្ទាត់ៗហត្ថកោសល់ ធ្វើមិនឆ្ងល់ក្នុងការដំណាក់ថ្មី។

ឯរោងលោកកុម្មីសែរតាំងខាងស្ពាន មានទាហ៊ានតាំងរានចាំប្រកតី
បន្ទាប់តរោងផ្ទុមក្រុមមន្ត្រី កណ្ដាលលោកស័ក្តិបីរាជអាជ្ញា។

ចុងខាងត្បូងគឺរោងលោកចៅហ្វាយ ព្រះដំបងតាំងរាយប្រជិតគ្នា
លោកស័ក្តិបីនាយត្រួតលើព្រះពញា ឲ្យកែល្អតាមយស្វាបណ្តាស័ក្តិ។

សឹងប្រដាប់ឈើស្រស់របស់ព្រៃ ក្រុងជាភ្លួងមាលៃបំពេនពាក់
ចងសំយុងជាភួងរបៃថ្នាក់ កែមចម្លាក់មើលចម្លែកភ្នែកលោកិយ៍។

ឯពួកចិនតែងខាងហាងដាក់ផ្សារ មានទំនិញសព្វប្រការគ្មានខ្វះអ្វី
ខ្លះតាំងរានលក់ភោជន៍ភ័សចំណី ស្លាបារីកាហ្វែតែនំបុំាង។

ខាងពួកខ្មែរអ្នកស្រុកលក់ចេកស្ងោរ នំចាក់កោរនំជាលន្ធូរនំបុំាង
ខ្លះក៏លក់នំបញ្ចុកលតបាយអាំង ខ្លះក៏តាំងរានមីរានសុរា។

បណ្តាពួកអ្នកទៅនគរវត្ត ពុំមានអត់នឹងស្បៀងលៀងជីវា
មានតែប្រាក់ក៏ទិញបានភោក្តា សែនមហាលោះលាយសប្បាយក្រៃ។

ដោយទីនោះធ្លាក់ទៅជាសមសាន លោកមករៀបជាស្ថានព្រះរាំងជ័យ
មើលសព្រាតភ្លឺជ្រះដាសទាំងព្រៃ ហាក់មឿងមានក្សត្រថ្លៃគង់ប្រក្រតី។

ឯខាងពួកបារាំងតាំងសាងតឹក មើលភឺលឹកប្រកសឹងស័ង្កសី
ជញ្ជាំងលាបបាយអពណ៌លឿងខ្ចី គ្រឹះពីដីផ្ទៃស្មើល្អបវរ។

ផ្ទះនោះឯងបែងរ៉ាប់ទីប្រជុំ លោកគូរវៃរណើរជាជំព្រៃនគរ
លោកអញ្ជើញមកដោយក្តីសាទរ សមោសររាជការនគរវត្ត។

ខ្ញុំបាទយល់ទីស្ថានលោកតែងថ្មី នឹកសរសើរបារមីព្រះចមក្សត្រ
គ្រាន់តែយាង១គ្រាក៏កើតចាត់ ទីព្រៃស្ងាត់ក្លាយកើតជារាំងស្ថាន។

ឱព្រះគុណប្រកបដោយបុណ្យក្រៃ លើសនិស្ស័យយើងពុំប្រមាណបាន
ខំឧស្សាហ៍ យាងមកទីបូរាណ ឲ្យព្រៃប្រែជាស្ថានបូរីរតន៍។

មើលក្រសិន្ទយល់ក្រសែជលេសាយ វាលវែងឆ្ងាយឱបអមនគរវត្ត
លោកជីកធ្វើជាគូរាំងស្កាតស្កាត់ មានចង្វាត់ខឿនខណ្ឌខាត់ពៃរី។

គន់គង្គាក្រសិន្ទវែងរវឹង ខឿនសុទ្ធសឹងថ្មដាដាសនាទី
ធ្លាក់ជារូបក្បាច់ហូតហៀនពេជី ដណ្តើរកាច់ក្បាច់ភ្ញីដកច័ន្ទចែង។

កណ្តាលថានមានស្ពានថ្មដាដាស ចំនួនក្រាស់ជាងសិនសែនគួរស្ញែង
តែកំណត់ទទឹងនឹងប្រវែង មានក្នុងក្បួនល៉ាយថែងលោកចែងទុក។

ខាងចុងស្ពានមានធ្លាជាបីផ្លូវ មានរូបគោឈរនៅគ្រប់មុមមុខ
គោសិលាខ្លះនៅពុំទាន់ពុក ខ្លះបែកមុខបាក់ក្រាញពីការកាយ៍។

អនិច្ចាគោថ្មលោកកសាង មើលថាថាងយ៉ាងរស់ស្ទុះប្រែប្រាយ
ឥឡូវមកឆ្ងាយធ្លាក់បាក់ខ្ចាត់ខ្ចាយ ស្តាយអើយស្តាយមិនគួរមកពីការ។

មានអ្នកព្រៃចង្រៃឥតគំនិត ទៅសំលៀងកាំបិតគ្រឿងប្រហារ
ឲ្យខូងខូចខាតសាច់បង់អសារ មិនស្តាយការស្នាដៃបូរាណសោះ។

ឱគោអើយគោឈរមិនមើលមៀង មកឲ្យគេសំលៀងខ្នងគោចុះ
ម្តេចមិនខឹងខាំវាសំលៀងនោះ ឲ្យវាលុះក្តីមរណ៍យវាទៅ។

អាណាអើយបំផ្លាញរូបគោលោក គ្មានប្រយោគឲ្យយល់ការរាក់ជ្រៅ
គួរឬលោកខំសាងតាំងទុកនៅ មកសត្រូវបំផ្លាញរបស់លោក។

គន់ៗ ស្ពានស្ពានថ្មតប្រជិត ជាក្តារថ្មដាសជិតប្រកិតគោក
ទោះដំរីបរជាន់ក៏គ្មានយោគ ឥឡូវជ្រោកស្រុតខ្លះតែដើរបាន។

ប្រកាន់ដៃឆ្មេរូបវាសុក្រី ដប់សិរសីដូចស្និតជិតជុំប្រាណ
លើកពពាទ្បើងពភ្លាក់ហាក់ហៅហាន សំដែងប្រាណប្រួញរូបជាមួយគ្នា។

មើលនាគរាជអង់អាចអំណាចស្ញែង ខ្លួនក៏វែងក្បាលក៏រក់តាមទ្វារា
លូនលើស្ពានមានជើងកល់គង្គា កន្ទុយបែកញែកគ្នាតាមធ្លាផ្លូវ។

ឱរូបវាសុក្រិតតក្រែងគ្រុឌ តាំងសម្តែងរិទ្ធិរុទ្ធតសត្រូវ
ប្រសិនគ្រុឌមកយល់យ៉ាងពុំនៅ គង់ស្ទុះទៅជ្រកក្នុងក្រសិន្ធុនេះ។

នាគអើយនាគបាសាណបូរាណ សាងពីដើមយាងល្អឯកដូចម្តេចឯះ
ឥឡូវនាគដាកធ្លាក់បាក់របេះ ឃើញតែរាងយ៉ាងនេះអស់លំអ។

ខ្លួនក៏ឃ្លាតក្បាលក៏ឃ្លៀងទៅដោយខ្លួន ឃើញតែក្បូនជើងទៀនប្រចាំទ្រ
ស្តាយអើយស្តាយស្នាដៃលោកតែងម មិនតាំងតថាវរៈឲ្យវែងទៅ។

ឱអនិច្ចាសង្ខារនាគាថ្ម ហ្មាយតស្ថិតស្ថេរចេរកាលនៅ
នេះពុំទាន់ប៉ុន្មានមកហ្មងសៅ មករុសរាយធ្លាយទៅទីទៃផ្តាស់។

មែនហ្ន៎សព្វសង្ខារក្នុងលោកិយ៍ មិនថាអ្វីតែកើតមកគង់វិនាស
ចុះត្រៃលក្ខណ៍ជាក់យ៉ាងពុទ្ធប្រកាស សង្ខារចាស់គង់ផ្តាស់ទៅទីទៃ។

អម្បាល់ថ្មគង់ប្រែរបេះបាន ចំណង់បើរូបប្រាណយើងសព្វថ្ងៃ
នឹងមានជាតិខ្លឹមសារឯណានៃ គង់បន្លែដោយដៃរោគបិន្ទា។

កើតជាកាយគង់ធ្លាយសូណ្យ៍ជីវី បំពេញព្រះធរណីតែរាល់គ្នា
គួរនឿយណាយបង្អន់ភ្លើងលោភា យកនាគានគរវត្តសង្កត់កាយ។

ខ្ញុំពិនិត្យគិតផ្លូវព្រះត្រៃលក្ខណ៍ ចិត្តមិនធ្លាក់ឲ្យចំអារម្មណ៍ហ្មាយ
នៅតែស្ទុះម្តងៗដល់ឆោមឆាយ ព្រោះឃ្លាតឆ្ងាយក្រែងឃ្លៀងលំអៀងទៅ។

ឱចិត្តខ្ញុំលោកិយ៍ដូចពានរ មិនដែលឈឹងនឹងឈរឲ្យនឹងនៅ
ឃើញឯណែះនឹកឯណោះមិនចុះផ្លូវ ថាតែក្រៅក្នុងមិនត្រេចភ្លេចក្តីត្រេក។

លុះដើរដល់រោងទងខ្លោងទ្វារប្រាង្គណ៍ របៀងខាងយ៉ាងខណ្ឌកន្ទ្បែងប៉ែក
ត្បូកណ្តាលមុខដាច់ជា ៤ ប៉ែក មានយ៉សែកបែកចុះជាពីរផ្លូវ។

ប្រាង្គណ៍កណ្តាលមានរូបទេព្វសិលា គឺអ្នកតាមហារាជប្រចាំនៅ
បួនព្រះករកាន់គ្រឿងភ្លឹសន្ធៅ មើលៗទៅគួរសម្ញើមស្ញើមមុហិមា។

ពួកអ្នកព្រៃរាប់អានជាទេព្វរ័ក្ស យកក្រដាស់មាសប្រាក់អុចបូជា
បន់អ្នកតាមហារាជរឿងរិទ្ធា សូមឲ្យកើតលាភាស្រីសួស្តី។

ខ្ញុំយល់រូបអ្នកតាហ័ត្ថាសាយ ទំនងព្រះនារាយណ៍រឿងវង្សី
ព្រោះបូរាណរាប់អានព្រះសូលី តសូរាធិបតីតាំងជាមុខ។

ពួកអ្នកព្រៃពុំស្គាល់យល់អម្នាច នាំគ្នាហៅមហារាជទៅទាំងស្រុក
ឱព្រះនារាយណ៍រឿងតេជវិសេសសុខ ផ្លាញវាមារទសមុខបានសុខា។

មើលដំណាក់ប្រាង្គណ៍ដាក់ព្រះនារាយណ៍ កំពូលបាក់ធ្លាក់ធ្លាយឆ្នុះសុរិយា
ឥឡូវមានគេធ្វើជាបញ្ហា ប្រក់ក្បឿងយើងជម្មតាការណ៍ផ្លៀងខ្យល់។

ទ្វារខាងត្បូងមានគ្រឹះប្ញសដល់ដី បររទែះសាលីទាំងសកល
ទោះដំរីទាំងកូបក៏ឥតទាល់ ចុងផ្លូវដល់មុខនាគជាដើមព្រាត់។

ផុតរោងទងរំលងខ្លោងទ្វារប្រាង្គណ៍ លោកសំអាងសាងជាកំផែងព័ទ្ធ
តាមក្រសិន្ធុឡោមជុំនគរវត្ត លោកកំណត់ទ្វារចេញជា៤ដាន។

ចូលទ្វារប្រាង្គណ៍ចេញខាងទិសបូព៌ា មានថ្នល់ផ្លាទៅត្រង់មុខព្រះលាន
លោកវិចិត្រដោយថ្មកជាស្ពាន សង្ខាងមានរូបនាគប្រកាន់ដៃ។

រយៈផ្លូវសិនមួយមានផ្លូវញែក ជាពីរប៉ែកចែកចុះទៅទីទៃ
ដល់កណ្តាលមានប្រាង្គណ៍ខាងស្តាំដៃ ពួកអ្នកព្រៃហៅថារោងក្រយា។

ប្រាង្គណ៍ខាងឆ្វេងគេហៅរោងចំណី មើលគួរបើសមពាក្យអ្នកព្រៃថា
មានផ្លូវចុះពីថ្នល់ដល់ដូចគ្នា តែឥឡូវទៅជាព្រៃដុះជិត។

រោងព្រះស្ទោយធ្វើដោយសំលាភ្នំ តាំងជាមុមមុខបីជាបីស្និត
ឥតកំពូលមានដំបូលលោកវិចិត្រ យ៉ាងសន្ថិតឥតភីនភាពស្មើផ្ទៃ។

ឱរោងត្រួមិនគួរមកដួះផ្លាយ    បាក់ខ្ទាត់ខ្ចាយអន្តរាយដោយពួជ្រៃ
គ្រាន់នឹងចូលទៅមើលក៏ស្លុកក្រៃ    សែនអាល័យស្តាយរោងខូចអសារ។

លុះដើរដល់មន្ទល់ផ្ទះបារាំង    លោកមកតាំងកសាងប្រាង្គពណ៌ថ្មដា
ឈ្មោះមោនសៀរកុម្ម៉ៃជាមេការ    ចៅភ្នាក់ងារទទួលជួសប្រាង្គណ៍ស្ថាន។

លោកឲ្យជីកអាចម៍ដីដែលលុបថ្មល់    ដរាបដល់គ្រឹះថ្មល់ពីបូរាណ
ថ្មឯណាដែលបាក់ធ្លាក់ចាកស្ថាន    លោកឲ្យដាក់តាមដានសណ្ឋានចាស់។

លោកមោនសៀរកុម្ម៉ៃដៃបារាំង    យកសីមាំងលាបផ្ទាប់ដូចក្រដាស់
ឯណាស្លែចាប់ខ្លាំងមើលមិនច្បាស់    លោកឲ្យលាងបោសប្រោសសំអាតចេញ។

ពួកគូ លីស៊ីឈ្នួលជួលធ្វើការ    កប្បូណ៌ឈើរើថ្មដាដាក់ពាសពេញ
ខ្លះបោសធ្លាថ្មល់រលីងឆិញ    អ្នកចូលចេញមិនមានជិតធូលី។

ខ្ញុំដើរដល់យល់ថ្មល់លោកសំអាត    ឃើញពួកជាតិខ្មែរយើងជាគូលី
នឹកអាណិតជាតិខ្មែរក្រដល់ទី    ទទួលការគូលីស៊ីឈ្នួលគេ។

គន់រូបរាងទុពលពោះកំប៉េះ    សក់ក្រញ៉ាញ់ខ្មៅក្រញ៉េះឆ្អែះដូចភេ
ទាំងស្លៀកពាក់សំពត់ក៏ខុសគេ    ឱខ្មែរទេម្តេចខុសនឹងយើងម្លេះ។

ឬពួកនេះជាជាតិសម្រែគួយ    អ្នកងារស្អួយលេខវត្តនគរនេះ
ឬជាពូងរដែគេកែឈ្មោះ    បានជាប្លែកយ៉ាងនេះគួរអនិច្ចា។

លុះដើរដល់មណ្ឌលទីរានហាល    ថ្មដាដាលក្រាលសឹងក្ការសិលា
ផ្ទៃពីដីពេជ្ររួតត្របកផ្កា    រៀបជាសារពើរសូត្ររួតថ្នាក់ៗ។

មានសរសេរថ្មឈូកជាញកចេញ    តាំងជុំវិញមានក្បាច់រំលេចដាក់
មានជណ្តើរកាច់ឡើងជាថ្នាក់ៗ    ចំប្រច័ក្ខឡើងចូលព្រះប្រាង្គណ៍ស្ថាន។

ផ្ទៃរានហាលកាលដើមបោះសំណ    លុះតៗដល់យើងអន្តរធាន
បាក់សំណនៅតែថ្មក្រាលជាលាន    របៀបរានរាបណែនសែនភិរម្យ។

គន់ប្រាសាទស្អាតប្រសើរដំណើរប្រាង្គណ៍    កំពូល៥បួនខាងខ្ពស់ត្រសុម
ថានរួតៗ រាល់ជាន់ជាពាន់ជុំ    ប្រាសាទធំតាំងកណ្តាលត្រដោមដុង។

រួតពីដីបីជាន់រោងទងជុំ    របៀងមុមមុខដាច់ក្បាច់រលង់
ជាហួតហៀនរៀនរាំងកញ្ចាំងចុង    ឈូកសម្បុ៉កឆែកសម្បុ៉ងជាខាន់ៗ។

ក្បាច់រងស្ស៊ូរទេពប្រណម្យដៃប្រណិត    លួសប្រកបល៉ាយប្រកិតភ្ញីវល្លិ៍វន្ទ
បៃរកាបាំងរកិតស្និតរយពាន់    របៀងខាន់របៀបខាត់ចាត់ស្មើគ្នា។

ឪជាងធ្លាក់រូបយក្ខធាក់ពានរ    យុទ្ធនារីករជាកោលា
រូបរាហូបៀមហៀនហង្សពាំផ្កា    យក្ខទេវតាទាញព្រាត់វាត់គិរិន្ទ។

មេក្របទ្វារបង្អួចក្បាច់របក    លកក្រចកផ្ទាប់មុខដូចគេមិន
ផ្ទៃក្ការផ្តែរឆ្លាក់រូបរាជទេវិន្ទ    តយុទ្ធនឹងអាសុរិន្ទរាជចិត្រា។

ជញ្ជាំងទ្វារឆ្លាក់ជាទេពរបាំ    ក្រោយលំនាំឈររាំក្បាច់កាច់ផ្កា
ខ្លះបួងសក់ខ្ទក់បីចងជដា    ខ្លះសំយាកកេសាសិតក្រជាំង។

ខ្លះពាក់មកុដកំពូលបញ្ចសឹង្គ    របៃមុខក្រឡឹងភាពកញ្ចង
ស្ងួរ៉ងកងអង្គន់ព្រះហត្ថ    ស្លៀកសម្ពុយថ្នក់បាំងក្រោមនាភី។

ចង្កេះរៀវជង្គងរ៉ាប់មួយក្តាប់ដៃ    មើលវិសេសសុទ្ធីវិស័យសមឥន្ទ្រីយ៍
សុគនក្បុំសមក្បួនន្ទួនមាលី    ភាពនរេតភេទនារីទីស្នេហា។

មានប្រុសយើងភ្លើងរាគវារោលខ្លាំង    ទៅអង្អែល “មំសំ” នាងសិលា
ឡើងរលង់សឹករលីងទាំងរូបា    គេស័ញ្ញាហៅថាស្រីមានលក្ខណ៍។

មើលមណ្ឌល់រោងទងទំនងស៊ុម    ជញ្ជាំងជុំសឹងជិតជាចម្លាក់
ជារូបរឿងរាមកេរ្តិ៍គឺរាមលក្សណ៍    ច្បាំងនឹងយក្ខក្រុងរាពណាសូរ។

ស្វាប្រចាក់យក្ខប្រចាប់រាំប់រងគ្នា
យក្ខប្រជិតស្វាប្រជាប់ចាប់កំពូល
ស្វាក្រទឹយក្ខក្រទាកប្បល័ផ្លាស់ប្តូរ
ស្វាប្រដាល់យក្ខដួលដេកក្បិនក្ប័យ។

គន់គំនូររឿងរាមសង្គ្រាមយក្ខ
ជ្រុងទីក្បិណគូរកាលសហស្សនៃយ
ជាអាណាក់មើលអណែកអនន្តក្រៃ
គង់នៅឰក្រៃឡាស់វិមានច័ន្ទ។

ក្រៃឡាសផ្លៀងផៀងធ្លាក់ព្រះសូលី
ដៃ២០មុខ១០រូបសកន្ធ
ប្រើក្រុងរាពណ៍អសុរិរាជកម្ព័ន្ធ
ឲ្យដម្រង់ប្រាង្គណ៍ចន្ទក្រៃឡាសស្ថាន។

រាពណានេរមិត្រវិទ្ធីសាហ័ស
ព្រះឥសូរក៏ទ្រង់ព្រះរាជទាន
ដម្រង់ភ្នំក្រៃឡាសឡើងត្រង់បាន
នាងមណ្ឌោកល្យាណជាភរិយា។

ផ្តែរខាងបូព៌ាគូរកាលសុគ្រីពយំ
ឲ្យជួយផ្លាញជីវិត្រនៃស្តេចស្វា
អង្វរអង្គព្រះបរមរាមា
ក្រុងពាលីជេដ្ឋាបច្ចាមិត្រ។

ព្រះរាមរាំប់ចាប់ធ្នូបួរប្លែងសរ
គូរទាំងពួកនារីស្រីស្ងំស្ងិទ្ធ
បាញ់ពានរពាលីសូណ្យជីវិត
សោកអាណិតសែនអាណោចខ្មោចពាលី។

ឯសុគ្រីពវិទ្ធីរុទ្ធបុត្រសុរិយា
អញ្ជើញអង្គរាមាចូលធានី
ក៏សោកានៅទៀបព្រះទែនទី
តាំងពិធីលើកសពពានរា។

ឯជញ្ជាំងខាងត្បូងគូរពួហបាទ
លើកជាក្បួនព្យូហយុទ្ធនា
ដង្ហែអង្គនរនាថកេតុមាលា
គ្រប់ភាសាចូលទាំងព្រះបារមី។

ខ្ញុំគន់មើលព្រះកេតុគេបិទមាស
សែនរុងរឿងថ្កើងបុណ្យព្រះចក្រី
គង់លើអាសន៍កណ្តាលពួកសេណី
ជាអស្ចារ្យផែនដីសកលអាយ។

អង្គនេះឬគឺជាបឋមក្សត្រ
ទ្រង់សាងព្រះនគរវត្តដំដើតឆាយ
គ្រងសម្បត្តិឥន្ទប័តវិសេសសាយ
ស្តេចលើកថ្វាយព្រះពុទ្ធឃោសា។

កាលលោកទៅចម្លងព្រះគម្ពីរ
វិលមកដល់ប្រទេសខេមរា
អំពីរាជធានីកោះលង្កា
ចមក្សត្រានិមន្តឲ្យលោកនៅ។

លើកប្រាង្គណ៍នេះប្រគេនជាមណ្ឌល
ពុទ្ធឃោសាចារ្យលោកគង់នៅ
ទីដំកល់ព្រះគម្ពីរគម្ភាពជ្រៅ
បានជាហៅនគរវត្តដោយកំណត់។

ព្រោះប្រាង្គណ៍នេះពីដើមជានគរ
ពួកបូរីនាំគ្នាមកសន្មមត្តិ
ដល់ក្រោយទ្រង់សាទរថ្វាយជាវត្ត
ហៅប្រាសាទនគរវត្តតាមបទមាន។

ឱព្រះគុណព្រះកេតុមាលាក្សត្រ
ថ្វាយជាវត្តសុរេចស្តេចចេញថ្កាន
ព្រះទ័យកាត់ពុំស្តាយព្រះរាជស្ថាន
ទៅតាំងស្ថានព្រៃក្មេងបេងមាលា។

ឥឡូវសូណ្យព្រះយសឈ្មោះបាត់បង់
ខ្ញុំបាទយល់សរសើរព្រះចេស្តា
ឃើញតែរូបព្រះអង្គគង់ច្នេះណា
លើកហ័ស្តាបង្គំគុណក្សត្រថ្លៃ។

គន់មើលព្រះកេតុមិនឆ្អែតក្តីសន្ធិះ
យើងឥឡូវគិតទៅអាចិន្ត្រៃ
ឱប្រាង្គ ណ៍នេះមើលទៅផុតនិស្ស័យ
មិនគួរទៅជាព្រៃសូណ្យអសារ។

យ៉ាងពីដើមមនុស្សច្រើនចំរើណចេះ
ស្នាដៃធ្វើមើលស្មើព្រះពិសកាម៌
បានជាធ្វើប្រាង្គណ៍នេះគួរអស្ចារ្យ
ឥតផុងដាស្អូលដែកសែកគ្នាជាប់។

ចោះក្លុងថ្មគង្ហឹតរលាយសាច់
នៅតែព្រង់អ្នកព្រៃប្រាជ្ញាអាប់
ដល់យូរមកដែករេចដោយច្រេះចាប់
ថាស្នាមម្រាមដៃចាប់មនុស្សបូរាណ។

ខ្លះសង្ស័យថាដៃព្រះឥន្ទ្រប្រើ
ខ្ញុំគន់ៗ មើលសព្វមន្ទិរស្ថាន
ឲ្យវិស្សកម្មធ្វើថ្វាយក្សត្រក្សាន្ត
មិនសមដៃមយវានលោកធ្វើឡើយ។

ព្រះឥន្ទ្រអ្វីមកធ្វើមិនឲ្យស្រេច
ខ្លះអាក្រក់ខ្លះល្អមិនស្មើឡើយ
មើលទៅក្បាច់ខុះគ្នាណាលោកអើយ
បើព្រះឥន្ទ្រធ្វើហើយគង់ស្មើគ្នា។

មួយវិញទៀតវិស័យទេព្វនិមិត្រ
តែស្តេចនោះលុះអស់ព្រះជន្មា
ធ្វើដោយរិទ្ធីគិតថ្វាយស្តេចអង្គណា
ទីនិមិត្រទៅជាផែនដីវិញ។

នេះប្រាសាទនគរនៅជាគឺ
នឹងថារិទ្ធីនោះឬយ៉ាងនេះមិញ
បើរិទ្ធីមែនម្លេះសមរលីងផិញ
ទីនេះមិញក៏ពេញទៅដោយព្រៃ។

សង្ស័យថ្មីនឹងដុំថ្មធំៗ
គេលើកយកទៅផ្គុំបានទាំងផ្ទៃ
គឺគេប្រើដោយយន្តរ៉ករវៃ
នឹងបានប្រើដោយដៃនោះក៏ទេ។

វិស័យជាងគេ ចេះគ្នាគេច្រើន
ស្តេចចំរើណដោយបុណ្យពីបុព្វេ
នឹងធ្វើអ្វីក៏ស្រេចចំណេះគេ
កុំទៅភ្លេចថាអង្គព្រះឥន្ទ្រសាង។

មានអ្នកខ្លះចូលចិត្តថាដីពិត
គឺគេដុតយ៉ាងឥដ្ឋជាថ្មប្រាង្គណ៍
ព្រោះឃើញទីក្រសិន្ធុដ៏នៅខាង
ទំនងយ៉ាងយកដីក្រសិន្ធុនោះ។

ឱហ្ន៎ជាតិអ្នកខ្មៅដៅមិនចំ
ម្តេចមិនមើលបែបពុម្ពតូចធំច្នោះ
មែនបើដីគេធ្វើមានពុម្ពនោះ
គង់ប៉ុនគ្នាអស់នោះមិនច្នោះឬ។

នេះមិនមែនប៉ុនគ្នាជាបែបពុម្ព
ខ្លះក៏ធំខ្លះក៏តូចនៅជាគឺ
បូរាណអ្វីឆោតម្លេះមិនដែលឮ
មកប្រឹងធ្វើដុំធំឲ្យធ្ងន់ក្រៃ។

បើយ៉ាងថ្មបាយក្រៀមនោះយល់មែន
ព្រោះផ្ទៃផែនស្មើគ្នាទាំងអស់នៃ
ឯថ្មផុកអ្នកស្រុកកុំសង្ស័យ
គឺសិម៉ង់ថ្មព្រៃយកពីក្រៅ។

បើមិនជឿអញ្ជើញទៅមើលដាន
ភ្នំខាងលើសឹងមានចំណាំងនៅ
ទាំងថ្មហ៊ុបថ្មដាប់គរតាមផ្លូវ
មានគេទៅបានឃើញជាអស្ចារ្យ។

ខ្ញុំគន់ មើលគំនូរគួរជញ្ជាំង
លើសកម្លាំងនឹងតែងឲ្យពិស្តារ
វិលត្រឡប់ទៅមើលជាន់កណ្តាល
ឃើញព្រះរោងជ្រះប្រាលក្រសាលលន់។

ជើងសសរឆ្លាក់រូបឥសីសិទ្ធី
អង្គុយបត់ជើងបិទប្រសិទ្ធីមន្ត
ផ្ទៃសសរមានអក្សរប្រកាសបុណ្យ
ឲ្យមហាជនមើលដឹងដំណឹងទី។

មានសករាជក្នុងរាជស្តេចជាន់ក្រោយ
ទ្រង់អំណោយសាងព្រះសាងគម្ពីរ
បានលែងមនុស្សជាខ្ញុំថ្វាយព្រះមុនី
តាំងសញ្ញីឈ្មោះទុកនៅមុខព្រះ។

លើពេតានផ្ទិម ខាត់ចាត់ក្បាច់ផ្កាយ
ឈូកសារ៉ាយល៉ាយលយលកល្បះៗ
គ្រឹះប្រដាប់បួនប៉ែកចែកស្រឡះ
ចន្លោះជ្រុងមានស្រះជា៤ដាន។

ឯស្រះនោះមានដក់ទឹកភ្លៀងស្អាត
មច្ឆាជាតិអាស្រ័យនៅជាស្ថាន
ឥតចកព្រាំស្មៅព្រៃផុកផង់គ្មាន
ផ្ទៃសណ្ឋាន៤ជ្រុងស្មើភាគគ្នា។

លោកប្រដាប់ដោយថ្មកដល់បាទ
រលីងស្អាតសឹងរួតហួតពេជា
មានកើយកែវជណ្តើរចុះគង្គា
មើលហាក់ជាស្ថានជ្រៅអណ្តូងជ្រោះ។

ខ្ញុំយស់ត្រីសង្ស័យហ្វូងមច្ឆា
មកពីណាទៅមានក្នុងស្រះនោះ
ស្រះលើប្រាង្គណ៍ផុតជាតិផែនដីសោះ
នឹងមានជ្រោះហូរជ្រាបក៏គ្មានមុខ។

ត្រីពួកនេះឧប្បត្តិកកើតឯងឬ
ឬមួយគឺគេយកមកលែងទុក
ខ្ញុំពឹះគ្រោះពុំឃើញមានទំនុក
សែនជាទុក្ខនឹងត្រីពេញអស្ចារ្យ។

នឹងមានអ្វីជាចំណីអាស្រ័យបាន
ចកសារ៉ាយក៏គ្មានជាអាហារ
មានតែស្លែដុះជាប់តាមថ្មដា
មើលអាការស្រះនោះជារណ្តៅ។

មានរោងទាំង៤មុមជុំស្រះស្រង់
ខ្នងបង្កង់ជាប់គ្នាជា៤ផ្លូវ
ទ្វារឧត្តរមានជ្រុងក្នុងយាងជ្រៅ
នរណាទៅគោះទ្រូងឮសូរគង។

មានអាការអស្ចារ្យទីនោះម្លេះ
បូរាណរិះចេះធ្វើមានទំនង
ផ្ទៃរាបស្មើពុំមានអ្វីរង
គោះតែទ្រូងឮគងសូរលាន់ៗ។

រោងខាងថ្បូងដំកល់ព្រះបដិមា
ពុទ្ធបាទសាស្តាហៅព្រះពាន់
អង្គខ្លះឈរខ្លះគង់សង្រួមខន្ធ
មានអរហន្តគង់គាល់ទាំងឆ្វេងស្តាំ។

អង្គព្រះខ្លះពិការបាក់ស្ទូរ៉ង
នៅតែដងអង្គកាយគង់ប្រចាំ
ព្រះខ្លះឈរកណ្តៀវ៉ាស៊ីសាំ
បែកព្រះកាយបាក់ព្រះកាំស្រាំព្រះករ។

មុខសថូបមានរូបច័ក្រពង្ស ពីរព្រះអង្គគឺព្រះកេតុចៅនគរ
គង់ប្រណម្យបង្គំមលើកព្រះករ ឱនស្មោះសរតគុណព្រះជិនស្រី។

តែរូបព្រះអង្គមួយដែលទ្រង់គ្រឿង ពាក់ជដារុងរឿងរឿងរង្សី
ខ្ញុំពុំស្គាល់ព្រះនាមជាស្តេចឰ្ល គ្មានចារិកនឹងស្តីថាស្តេចណា។

គន់ព្រះរូបចិត្តរួញកង្គួញក្រាប សិរោរាបបង្គំមព្រះសាស្តា
សូត្រសរសើរពុទ្ធគុណអនន្តា ស្រេចទើបលាឡើងទៅជាន់ទី ៤ ។

ថានខាងលើលោកធ្វើជាផ្ទៃរាន ជួរជុំមានសសរចេញដោយខ្លួន
សឹងក្រឡឹងជើងទៀនដ៏មាំមួន មើលសំនួនប្រមាណជារយប្លាយ។

ខាងឆ្វេងស្តាំមានកឹងទាំង ២ ដាច់ ប្រកបក្បាច់ខ្ចក់ហៀននឹងលួសលាយ
តួកឹងនោះតឡូវបាក់ធ្លាក់ធ្លាយ គួរតែស្តាយកឹងថ្មអន្តរធាន។

មើលបរិវេណចង្វាត់ព្រះប្រាង្គណ៍ធំ រោងទងជុំតាមជាន់គ្រប់ៗដាន
មានញូកញោចរូតពេជ្រតាមសណ្ឋាន លើសប្រម៉ាណនឹងវាស់កត់នីយម។

គន់ទី ៤ ប្រាង្គណ៍ ៤ ចតុរស កំពូលខ្ពស់ស្មើគ្នាទាំង៤មុម
ខ្ញុំក៏ឡើងជាន់ ៥ ប្រាសាទធំ ខ្ពស់ត្រសុមមើលត្រសែតអណ្តែតចិត្ត។

ភាពជណ្តើឡើងទៅក៏ខ្ពស់ចោត កាំនោះសោតតូចៗ ជាន់មិនស្និត
ប្រកាន់ដៃពុំមាននឹងយោងយិត ខំកខិតឡើងទៅត្រាតែដល់។

គន់ជណើរឡើងទៅ ៩ ស្ថាន ក្នុង ១ ដានពីរៗ ជុំមណ្ឌល់
មានរូតថ្នាក់ល្បាក់ញូកលោកដំកល់ ជាពើងទល់ទាល់ដល់ប្រកាន់លើ។

តួប្រាង្គណ៍ទាំង ៥ យ៉ាងចេតិយ៍ រូត ៩ ជ្រុង ៨ ជាស្មើៗ
ខឿនប្រដាប់ពេជ្ររូតច្រើនអន្លើ គ្របកស្មើជ្រុំងមុមទាំង ៤ ដាន។

មានទ្វារចូល ៤ ទិសតែគេទាស់ បិទជិតអស់មិនឲ្យចូលទៅបាន
ស្អាងជាអង្គព្រះឈរប្រតិស្ឋាន ប្រចាំដានគ្រប់ទិសទាំង ៤ ទ្វារ។

ខាងក្នុងប្រាង្គណ៍យ៉ាងដាក់ព្រះមាសប្រាក់ ដែលបែកបាក់ធ្លាក់បង់អង្គពិការ
ឬរបស់ឯណាជាខ្លឹមសារ ក្រែងពួកចោរពួកមារវាយាយី។

លោកមោនសៀរកុម៉្មែចៅភ្នាក់ងារ ឲ្យដាប់ទ្វារខាងថ្បូងរូបព្រះជីវ៍
រំលើងអង្គព្រះទ្វារចេញចាកទី រើយកព្រះខ្មែចខ្មីពីក្នុងប្រាង្គណ៍។

ខ្ញុំយល់អង្គព្រះទ្វារគេដាប់ម្តេច បាក់ស្លូវ៉ងរូបខ្មែចមិនយល់រាង
នឹកសង្វែកព្រះទ្វារគេរំលាង ផុតរំវាងសាស្នាព្រះទ្វារហើយ។

ព្រះទ្វារទាំង ៣ លោកគង់សុខ ពុំមានទុក្ខដូចអង្គព្រះថ្បូងឡើយ
ឱព្រះថ្បូងពីថ្ងៃនេះទៅហើយ រំលត់ខន្ធកាត់ត្រើយនិព្វានហោង។

ខ្ញុំខំចូលទៅមើលកន្លែងគុក ដែលគេតាំងព្រះទុកពុំឲ្យហ្លួង
មើលមិនច្បាស់ព្រោះជះក្លិនម្តងៗ គឺប្រចៀវខ្មៀវកងវាឧច្ចារ។

ទើបលាថយចុះមកត្រិះធរណី មើលពួកខ្មែរគូលីគេធ្វើការ
ជញ្ជូនយកអាចម៍ដីគឺឧច្ចារ ចេញតាមទ្វារទិសបូព៌បង្ហូរគ្នា។

គន់មណ្ឌលព្រះប្រាង្គណ៍យ៉ាងល្បោលៗ ពេលក្របីចូលក្រោលអស់សុរិយា
ខ្ញុំនាំគ្នាចុះមកកាន់ពសុធា ទៅរកទីនិទ្រានារាត្រី។

លុះព្រឹកឡើងជាថ្ងៃមួយដណ្តប់ តិត្ថីជូនគំរប់ថ្ងៃសៅរិ៍
លោកចៅហ្វាយក៏ដល់មណ្ឌល់ថ្មី ថែងសេចក្តីថាថ្ងៃនេះហ្លួងដល់។

ខ្លួនលោកមកជាមុនដោយប្រញាប់ នឹងអាលមកចាត់រ៉ាប់ឯមណ្ឌល់
ស្តេចនឹងយាងមកតាមវិថីថ្នល់ កំណត់ម៉ោង១១ដល់ព្រះពន្លា។

លុះនិយាយបានតិចលេចកៅរិ៍ ជិះពាជីមកដល់ថែងកិច្ចា
ជុំរាបលោកសក្តិ៍ ៣ រាជអាជ្ញា ថាឲ្យរៀបព្រះពន្លាស្តេចដល់ឆាប់។

លោកស័ក្តិពញច្មោះស្មុះម្ទីម្នា ហៅពួកក្រុមឃោផាជាប្រញាប់
ព្រមទាំងពួកខុននាងគ្រប់សម្រ័ប ឲ្យរៀបខ្លួនឈររ៉ាប់ព្រះចក្រី។

ក្រុមទាហ៊ានក៏រៀប ក្បួនសលុត ឈរបារុធរន្ទីយ៉ាតាមថ្នល់ថ្មី
ពួកអ្នកស្រុកក៏ផ្អើលទាំងប្រុសស្រី មកចាំមើលចក្រីមិត្រៀបត្រា។

ខ្លះក៏បីកូនតូចដឹកកូនធំ អាតូចយំអាធំយិតស្ទើរដាច់ស្មា
ខ្លះក៏បាត់ប្អូនឃើញបងរកគ្នាឆ្លា ខ្លះឃើញយាយបាត់តាហៅគ្នាស៊ាន។

ខ្ញុំគន់ៗ អ្នកព្រៃចង់តែសើច ត្រកូលខើចមើលខាតខុសសណ្ឋាន
ទាំងស្លៀកពាក់មិនសមនឹងខ្លួនប្រាណ សែនរំខានទាស់ ភ្នែកប្លែកកន្លង។

មានយាយចាសខ្លះនោះរូបពន្លក់ ទៅពាក់ការទំពក់ដូចគេចង
ពាក់អង្គាំចារស្លាន់ព័ន្ធកម្រង មើលម្តងៗចុះគន្លងព្នងពិតៗ។

ឱអ្នកព្រៃតែងតួតតសម្លម ពុំចេះរៀបចេះចំតាមចារិត
គន់អ្នកព្រៃមិនអសក្តិអាណិត ហេតុតែក្រពិតៗទើបយ៉ាងនេះ។

អនិច្ចាអ្នកក្រត្រដមក ខំប្របៀតជ្រៀតជ្រកនឹងគេច្មេះ
ខ្ញុំសម្តេទបានតិចលេចឃើញសែះ ក្រម្ការគេជិះជាមគ្គទេស។

ឃើញព្រះទីនាំងរាជរថពីរបវរ ទិមអស្សូត្តររបរចូលដល់និវេស
ទ្រង់យាងចុះលោកធំបារាំងសែស គំនាប់តាមប្រទេសវេណីក្រៅ។

នាយទាហ៊ានក៏ស្រែកក្បួនសលុត ចាប់អាវុធរន្ទីយាប័ញ្ឈរនៅ
ពួកនាហ្មឺនឱនកាយបង្គំទៅ ទ្រង់រ៉ាប់ផ្លូវបដិសណ្ឋារា។

លោកស័ក្តិពាទទួលទីរ៉ាប់រង ជាបាលដ្ឋទួលស្នងការនានា
គំនាប់ស្រេចស្តេចឡើងកាន់ព្រះពន្លា អស់ព្រះពញាហែឡើងដំណាក់ស្ថាន។

ដល់ព្រះទែនស្តេចទ្រង់គង់កៅអី លោកស័ក្តិពាអនុកូលទូលរ៉ាយង៉ាន
រឿងអ្នកទោសដែលចាប់ពីក្រៅស្ថាន កាលពីស្រុកមោះមានអាចោរខ្លាំង។

លោកឲ្យចាប់ទាំងជាទាំងកាចមក ព្រោះប្រាថ្នាដកយកស្បៀងកម្លាំង
នៃអាចោរទុច្ចរិតគិតតតាំង កាត់កម្លាំងពួកចោរមិនឲ្យនៅ។

បានជាកៀរគ្រួមកព្រះដំបង ដាក់ទោសតាមទំនងដែលហួងសៅ
ចាំស្រុករាបកាលណានឹងលែងទៅ ដល់តឡូវស្រុកក្សាន្តបានសុខា។

គួរមេត្តាយ៉ាងណាស្រេចតែទ្រង់ ឬបង្អង់ឈប់រង់មើលក្សិណរា
ព្រះចមយសជ្រាបច្មោះទ្រង់មេត្តា ឱ្យលើកកាត់ទោសាពួកអ្នកព្រៃ។

សន្ទនាបានតិចតាមនុសន្ទី ឲ្យនិមន្តព្រះសង្ឃចូលថ្វាយជ័យ
ជយន្តោថ្វាយពារក្សត្រថ្លាថ្លៃ តាមនិស្ស័យវេណីពីបូរាណ។

លោកសង្ឃយើងព្រះដំបង ១០ អង្គគត់ វិន័យធរដើមបទជាប្រធាន
រៀបព្រះអង្គចូលកាត់ព្រះរាំងស្ថាន ទទួលក្តីរាប់អានតច័ក្រា។

ទើបថ្វាយព្រះជយន្តោពរភវ័ត ចំរើនរាជពិភ័តមង្គលា
លុះចប់ស្រេចស្តេចត្រាស់សន្ទនា ឲ្យសង្ឃលាទៅស្រុកតាមសម័យ។

ព្រោះក្រែងដាច់វស្សាការសៅហ្មង តាមទំនងសត្តាហ ៧ ថ្ងៃ
លោកស័ក្តិ ៣ ទទួលទូលកែខៃ សូមអំណាចក្សត្រថ្លៃឃុំវស្សា។

ច័ក្រពង្សពុំទ្រង់ឲ្យអំណាច ព្រះទ័យខ្លាចក្រែងខុសក្នុងសិក្ខា
តែសត្តាហព្រះដំបងហួសហើយណា ហ្លួងនឹកថាក្រែងលោកទើបដល់ថ្មី។

ពុំជ្រាបហេតុព្រះសង្ឃព្រះដំបង មកនៅចាំរ៉ាប់រងព្រះចក្រី
តាំងពីខ្នើត ១ កើតចូលតិត្ថិ ១១ សៅរ៍ហួសកំណត់។

សត្តាហបានតែ ៧ ថ្ងៃ នេះហួសផុតនិស្ស័យសិក្ខាបទ
ថ្ងៃហ្លួងដល់ ១១ កើតប្រាកដ បើកំណត់សត្តាហហួស ៤ ថ្ងៃ។

ហេតុដូច្នោះលោកសង្ឃព្រះដំបង ដាច់វស្សាហើយហោងកុំសង្ស័យ
ខ្ញុំឮច្នោះអាណិតលោកពេកក្រៃ ឱម្ចាស់ថ្លៃត្រង់កបិនឃើញជាខាន។

មួយអាណិតតែលោកវត្តនិវេស ជាប្រទេសមង្គលបូរីស្ថាន
ត្រូវទោសខុសកាលស្រុកកើតមោះមាន ពួកទាហ៊ានចាញ់ចោរវរកល្បុគ។

លោកភ័យលោករត់ទៅនៅណោងបួ ដល់ស្រុករាបនាំគ្រួសិស្សវិលស្រុក
លោករាជការថាលោកនាំកល្បុគ ឲ្យឃុំខ្លួនមកទុកព្រះដំបង។

ឃាំងនៅវត្តពីភិតជាយូខែ ទម្រាំតែផុតទោសដែលមោះហ្មង
មិនដឹងជាថ្ងៃណានឹងរួចហោង សែនមួហ្មងចង់វិលទៅវត្តវិញ។

រកឱកាសពុំបានរំខានចិត្ត សែនអាណិតគិតទៅគួរតែម្នេញ
លុះឮការថាហ្លួងស្ដេចយាងចេញ ចាកភ្នំពេញមកផ្គំនគរវត្ត។

បានឱកាសដោយចេះក្បួនរន្ទា កាំជ្រួចភ្លីគោហ៊ាសម្រែកសត្វ
លោកវត្តលៀបមេការទីបាល័ដ្ឋ លោកក៏ចាត់ឲ្យទៅជាមួយផង។

ឲ្យលោកជួយការភ្លីទីឆ្លងបុណ្យ ថ្វាយព្រះគុណជាគុណព្រះច្បាស់ច្បង
បានឱកាសនឹងទូលសូមទោសហោង នឹងបានវិលទៅគ្រងនិវេសវិញ។

លុះឮហ្លួងប្រោសលែងអ្នកទោសបង់ ទាំងបាសកលោកសង្ឃដូច្នោះមិញ
មួយលោកសង្ឃ ៣ អង្គនៅភ្នំពេញ ឲ្យវិលវិញមកនៅតាមដើមដាន។

ចៅអធិការនិវេសក៏ស្បើយទុក្ខ មានទឹកមុខរីករាយសប្បាយបាន
ថ្វាយព្រះពរលាអង្គចមក្សត្រក្សាន្ត វិលទៅស្ថានទីលំនៅនៃអាត្មា។

ចមរាជាសន្ទនានឹងព្រះសង្ឃ លុះសុរិយង្គរះរេជ្រេឆាយា
សង្ឃទាំងឡាយក៏ថ្វាយព្រះពរលា ព្រះរាជាទ្រង់សោយដោយសម័យ។

ស្ដេចទ្រង់សោយព្រះស្ងោយវេលាជ្រេ សូរេចសោយសុរិយេជ្រេសែងថ្ងៃ
ទ្រង់បន្ទុំសំរានព្រះហឫទ័យ ពួកខាងណៃទាញផ្លិតផាត់ថ្វាយទ្រង់។

សែនកំសាន្តក្សាន្តភិរម្យបរមនាថ ព្រះពាយផាត់គន្ធជាតិពិដោហ្វង់
មហោរីប្រគំបន្លែងអង្គ ចក្រពង្សទ្រង់ផ្ទំភិរម្យខ្ជ័ន។

លុះទិនករចរបែរជ្រេរស្មី ព្រះចក្រីតើនចាកទែនសុវណ្ណ
តែងព្រះអង្គចេញគង់ចុងរោងច័ន្ទន៍ ពួកកំណាន់គាល់រ៉ាប់ស្ដាប់ឱង្ការ។

អស់ជុំនុំមន្ត្រីកុង្សីយធំ មកដល់ជុំចាត់ទីតាមមុខងារ
ក្រុមបោលិះតាំងនៅប្រចាំទ្វារ មើលត្រួតត្រារក្សាសត្រូវទ្រង់។

ពួកក្រុមវាំងលោកវាំងនាយចាងហ្វាង ភ្នាក់ងារខាងស្ដីការស្នំខាងក្នុង
ក្រុមដំរួតនាយត្រួតព្រះដរង្គ លោកព្រះស្ដេចស្ដីការក្នុងសង្ឃការី។

អគ្គរាជយមរាជក្រុមមឿង សត្រីរឿងអាជ្ញាការផែនដី
ក្រឡាហោមចក្រីទីកុង្សីយ៍ ភ្នាក់ងារស្ដីតាមទីចតុស្តម្ភ។

ឯខុនណាងខាងក្រៅណកដំណែង ភ្នាក់ងារតែងគ្រប់មុខទាំងតូចធំ
សឹងព្រមព្រៀងនៅរៀងរោងថែវធំ តាមក្រុមៗខ្ញុំពុំស្គាល់ទេលោកអើយ។

គ្រាន់នឹងតែងឲ្យគ្រប់ឈ្មោះអស់លោក គិតប្រយោគទៅទៀតពុំបានឡើយ
ពេលក៏ជួនចុះយប់ព្រលប់ហើយ ខ្ញុំក៏នឿយវិលទៅទីនិទ្រា។

ពេលយប់នោះការហ្លួងទើបដល់ថ្មី ក្រុមមន្ត្រីសំរ៉ាកតែរាល់គ្នា
ពុំទាន់មានរាជការនឹងពណ៌នា ខ្ញុំនិទ្រាលក់ទៅតាមសម័យ។

លុះព្រឹកឡើង ១២ ថ្ងៃអាទិត្យ ចមបពិត្រព្រះកែវហ្វាសុឡាឡៃ
ស្ដេចរៀបគ្រឿងព្លីការបូជាស័យ សូមពរជ័យទេវតារក្សាស្ថាន។

មួយបូជាព្រះពាន់ពុទ្ធរូប នៅព្រះសថូបចេតិយ៍ពីបូរាណ
ទាំងអ្នកតាមហារាជរិទ្ធីហាន តាមលំអានបូរាណរាជវេណី។

លុះដល់ថ្ងៃ ១៣ តិត្ថិថ្ងួន ពួកខុននាងរៀបខ្លួនគ្រប់នាទី
ចាំទទួលលោកធំចៅធានី គូរ៉ែរណើរមកពីព្រៃនគរ។

លុះលោកដល់ក៏ចូលទីប្រជុំ ពួកមន្ត្រីតូចធំគ្រប់និករ
សឹងទទួលគំនាប់ដោយសាទរ ចមនគរក៏ទ្រង់ត្រេកគំនាប់។

លោកស័ក្តិ ៣ ថែមថីបកភាសា ថែងកិច្ចាទទួលក្រសែសព្វ
ច័ក្រពង្សក៏ទ្រង់គង់ប្រថាប់ តាមព្រះច្បាប់ស្តេចទ្រង់គង់ស្តាំដៃ។

លុះសុរេចសន្ទនាវេលានោះ គូរ៉ែរណើរលាចុះឡើងរថរ៉េ
ទៅផ្ទះខាងថ្បូងព្រះវាំងជ័យ សំរាប់ទីអាស្រ័យបារាំងនៅ។

ខ្ញុំមើលស័ក្តិ៥ចាំមិនដាក់ ឃើញតែពាក់គ្រឿងស័ក្តិប៉ាក់ប៉ានឆ្នៅ
រូបលោកទាបភាពធាត់មាត់ស្រម៉ូវ មើលៗទៅគួរខ្លាចពុំអាចជិត។

គេចមកមើលអ្នកលេងល្បែងបៀប៉ោ ខ្លះក៏ចាញ់សោកះប៉ៅស្ងិត
ខ្លះបានឈ្នះក៏ត្រេកដម្រេកចិត្ត ខ្លះរេគិតកែកុនដោយកល់កោង។

ខ្លះឈ្នះប៉ោចាញ់បៀសៀរជួ ចាក់១តៅខុស១តួក៏ស្មើយស្បោង
បែត្រឡប់ប្តូរប្រាក់ចាក់អាប៉ោង ត្រូវចិនកោងអស់ប្រាក់ធ្លាក់ចង្កា។

ចាប់យីគីស៊ុ ១ សងដល់ ១០ ចិនប្រសប់លខ្មែរកែបញ្ញា
ទោះជាត្រូវយូរទៅគង់អប្បរ៉ា បានដៃវាដាក់ថង់កុំសង្ស័យ។

ខ្ញុំមើលគេរេគិតដល់ខ្លួនឯង មិនគួរលុះការល្បែងឲ្យចង្រៃ
ទុកទិញបាយចំណីត្រីអាស្រ័យ យល់ជាមានកំរ៉ៃបានឆ្អែតពោះ។

ឯជាតិល្បែងលេងភ្នាល់មិនទាល់ថែះ ឈ្នះឯណុះចាញ់ឯណេះមិនខានសោះ
ការលោភលង់គង់លាញប្រទាញឈ្មោះ តែដល់គ្រោះគង់ក្រកម្រក្រៃ។

ខ្ញុំមើលគេបានតិចគេចទៅផ្សា ទិញចំណីអាហារបាយអាស្រ័យ
សូរេចកិច្ចសុរិយេជ្រេមាត់ព្រៃ បាត់សែងថ្ងៃខែខែរង្សីសែង។

ចៅភ្នាក់ងារនាំគ្នាតែងរោងរាំ ទាំងរោងទងឆ្វេងស្តាំសឹងខ្វាត់ខ្វែង
អុចប្រទីបផ្កាលាភ្លើងភ្លឺទែង ជាជួរវែងដល់ចុងផ្ទះបារាំង។

លើខ្លោងទ្វារអុចជាត្រាផែនដី មកុដខ័នរង្សីព្រះពានតាំង
ស្វេត្រឆ័ត្រឆ្វេងស្តាំប្រចាំបាំង ភ្លឺទូទាំងរាជវាំងត្រឆាឆាយ។

មើលពន្លឺកគ្រឹកគ្រឹនអាណែកក្រៃ ស្វាងទាំងព្រៃដាលដាស់ឱភាសសាយ
បណ្តាពួកប្រុស ស្រីផងទាំងឡាយ សឹងសប្បាយនាំគ្នាមើលត្រៀបត្រា។

លុះដល់ពេលហ៊ុមរោងភ្នាក់ងារហ៊ោ ភីរីរោណៃណកជើតឈឹងឆា
ពួកអ្នកស្រុកក៏ចូលមើលត្រៀបត្រា ណែនទាំងមហារាជរោងកងសព្វសែ។

សឹងប្របៀតជ្រៀតគ្នាជែកមិនចុះ នរណាលុះក៏ស្ទុះទៅមុខគេ
នរណាខ្លាចមិនអាចប្របៀតទេ ត្រូវឈរមើលក្រោយគេឃើញត្រដ។

នរណាខ្ពស់គេគ្រាន់មើលស្រួលរាប នរណាទាបតោងរកជើងម៉ាត
បើស្រីណាកាន់ខ្លួនថាន្ទនល្អ តែចូលទៅក្នុងចគង់អប្រីយ៍។

ពួកអ្នកលេងវាតែងដើរត្រដុះ ជាច្នេះច្នោះឱ្យលុះការលោកីយ៍
ខ្ញុំយល់ៗអាណិតពួកសត្រី ប្រុសអប្រីយ៍យាយីជាទីហ្មង។

ខ្លះមានញាតិបងប្អូនជូនព្យាបាល រក្សាការណ៍ពួកពាលពុំកន្លង
ឯណាគ្មានពូចពង្សវង្សផៅផង ពាលវាលងឡូកលួនកួនដោយកាម។

អនិច្ចានារីរូបស្រងាំ មិនគួរមកមើលរាំឲ្យពាលតាម
ជាកូនចៅនរណាម្តេចមិនហាម បណ្តោយតាមចិត្តកូនឲ្យខូចច្នោះ។

ខ្ញុំឃើញគេឱចារការគួរស្អប់ គេចត្រឡប់ចាកចេញពីទីនោះ
ដើរមកក្រៅមើលភ្លើងគេអុចប្រុះ ខំដើរឆ្ពោះទៅស្តាប់ភ្លេងបារាំង។

ឃើញទាហ៊ានខ្មែរយើងរូបក្មេងៗ ឈរដំកង់តាំងលេងនៅមុខវាំង
មាននាយត្រួតបន្លឹសព្ទដូចស័ង្ខ ស្ករមួយតាំងក្រាំងៗតាមចង្វាក់។

ត្រៃតូចៗដូចក្លុយខ្លះរៀនជុំ ត្រៃធំៗរុំឆ្វាយដូចជាឆ្វាក់
កាន់សៀវភៅរាល់ដៃផ្ទុំមើលថ្នាក់ ខិតៗដាក់តាមចង្វាក់ព្រមៗគ្នា។

សែនពិរោះសព្ទត្រែសេលាន់កង ចប់ចុះម្ដងឡើងថ្មីបំភ្លែឃ្លា
មេឡើងហែបកូនឯបប្រសប់គ្នា ស្ដាប់ហាក់ជាភ្លេងកម្ពុទ្ធលាន់ឮសាយ។

ពួកបារាំងរៀបតាំងលៀងសុរា សព្វក្រយាអាហារគ្រឿងពីនាយ
បោយបំរើទាញផ្លិតជាប់រំភាយ កំសាន្តកាយដោយភ្លេងលេងប្រគំ។

លុះម៉ោង ១០ ជួនយប់រួចការលៀង ពួកបារាំងព្រមព្រៀងទាំងតូចធំ
នាំគ្នាដើរមើលការទីប្រជុំ សែនភិរម្យលោះលាយសប្បាយក្រៃ។

ពួកអ្នកលេងដើរទិញបារីស្លា ខ្លះចូលស្រាក់ទិញស្រាអាស្រ័យ
ពួកអ្នកលក់ឃើញមនុស្សទិញច្រើនក្រៃ ដំឡើងថ្លៃយកកំរៃលើសប្រក្រតី។

លុះព្រឹកឡើងថ្ងៃជ្រេព្រះទិនករ ចមភូធរចេញគង់ព្រះរោងថ្មី
ព្រមវង្សានុវង្សក្រុមកុង្សីយ ទាំងមន្ត្រីតូចធំជុំត្រៀបត្រា។

មានដំម្រាស់ត្រាស់ឲ្យចាត់ចែងទី រាជពិធីចំរើណព្រះជន្សា
មន្តព្រះសង្ឃសូត្រមន្តតាមវេលា ចំនួនគ្រប់ជន្ម៉ា ៧០ ប្លាយ។

លោកមង្គលទេពាចារ្យធំបំផុត ចំណែកខាងធម្មយុត្តិសង្ឃទាំងឡាយ
លោកមហាភិមនកបភិប្រាយ ជាពួកខាងមហានិកាយអធិបតី។

ព្រមព្រះគ្រូរាជាគណៈក្រៅ សឹងផ្ទុំនៅនាចុងព្រះរោងថ្មី
ថ្វាយពុទ្ធមន្តចំរើនរាជសួស្តី មង្គលកិច្ចរុំណើស្រីសវត្ថិ៍។

ចក្រពង្សទ្រង់តាំងលោកពុទ្ធវង្ស ប្រោសឲ្យគង់ក្នុងដែននគរវត្ត
ខាងអាចារ្យបាសកចេះបរិយត្តិ គឺអាចារ្យអ៊ុំមគាត់ចេះសាស្ត្រ។

ប្រោសប្រទានគ្រឿងយសអាចារ្យអ៊ុំម ឡើងជាធំទីសទ្ធម្មមេធា
ជាចាងហ្វាងខាងពួកត្រៃវិជ្ជា ប្រចាំនានគរវត្តប្រាកដហោង។

លុះពេលយប់អុចកាំជ្រួចរន្ទា ភ្លឺគោហានូវគ្រឿងដទៃផង
ពួកលខោនក៏រាំដូចសព្វដង អស់មនុស្សផងមកមើលដូចសព្វគ្រា។

លុះដល់ថ្ងៃ ១៥ វេលាព្រឹក មានពិធីផឹកទឹកព្រះសច្ចា
ប្រជុំពួកមន្ត្រីសេវកា ព្រាហ្មណ៍ហោរាជាធំក្នុងពិធី។

តាំងនៅនាព្រះភ័ក្ត្រនៃព្រះពាន់ ព្រះចមខ័ណ្ឌក៏ទ្រង់យាងចរលី
នាំព្រះវង្សកុង្សីយ៍ក្រុមយោធី ឡើងកាន់ទីប្រាង្គណ៍ធំប្រជុំការ។

លោកស័ក្តិ ៥ ស័ក្តិ ៣ ព្រៃនគរ ក៏ស្មោះសរចរតាមព្រះភូវនារដ្ឋ
ទាំងនាហ្មឺនក្នុងក្រៅគ្រប់មុខងារ ទទួលការទានទឹកប្រនិធាន។

លុះជុំព្រមព្រាហ្មណ៍ហោរសូត្រពិធី ប្រនិធានតាមទីពីបូរាណ
កូរអាវុធចុះជាទិព្វញាណ សូរេចទើបរាជទានក្រុមនានា។

ចៅហ្វាយខែត្រសៀមរាបព្រះដំបង ជានាយកងក្រុមក្រៅព្រះរដ្ឋា
លោកកុង្សីយអធិបតីក្នុងសីមា ទទួលទឹកព្រះសច្ចាការភិរម្យ។

លុះសូរេចពិធីទឹកសម្បថ ចក្រពត្តិក៏ទ្រង់គង់ប្រជុំ
គូរ៉ែវណើររេស៊ីដងត៍កំពង់ធំ គាល់ប្រជុំជំនំតាមកិច្ចា។

ទ្រង់ឲ្យហូតនាទីអាជ្ញាហ្លួង នាយក្រសួងសក្តិ៍ ៣ រាជអាជ្ញា
ទាំងលោកជំកម្ទីសែរជាតស្សរា ឲ្យផ្លាស់វិលភារាភ្នំពេញហោង។

យកលោកជំរេស៊ីដងត៍កំពង់ស្វាយ ឡើងជានាយកម្ទីសែរព្រះដំបង
មួយរាជកាសុខទុក្ខអស់រាស្ត្រផង ចៅហ្វាយខែត្រព្រះដំបងជាតស្សរា។

លុះប្រជុំរួចស្រេចស្តេចវន្ទី    អញ្ជលីលារូបព្រះសាស្តា
ទ្រង់យាងបាទចេញតាមទ្វារបច្ឆិមា    ព្រមព្រះវង្សពង្សាហែចេញថ្កាន។

ពួកអ្នកថតថាំថតព្រះរូបទ្រង់    ឲ្យជាប់ជុំទាំងវង្សព្រះប្រាង្គណ៍ស្ថាន
ខ្ញុំឃើញគេពេញកោតគេចំណាន    ថតយកបានព្រះឆាយកាយភូធរ។

លុះយាងដល់រាហាលមុខព្រះលាន    ពួកទាហ៊ានបារុំផសៈលុតឈរ
ស្តេចឡើងគង់ព្រះសៈលៀងរាជបវរ    ពួកអ្នកសែងហែចរចូលវាំងថ្មី។

លុះដល់ស្រេចស្តេចចូលព្រះរោងធំ    ថ្វាយបង្គំព្រះសង្ឃទាំងចាស់ខ្ចី
អង្គាសភត្តភេសជបាយចំណី    ក្រុមសង្ឃការីបាត់ការចង្ហាន់សង្ឃ។

ព្រះសង្ឃសូត្រទទួលរាជភត្ត    តាមកំណត់ពេលនោះថ្ងៃទៀបត្រង់
សូរេចកិច្ចសង្ឃលាព្រះចក្រពង្ស    ស្តេចក៏ទ្រង់ចូលកាន់ព្រះពន្លា។

លុះដល់ពេលសូរិយេជ្រេស្រទន់    ឲ្យនិមន្តព្រះសង្ឃសង្គាយនា
ចំនួនអង្គ ១០០ ដោយគណនា    លោកទេសនាត្រៃ ៣ តាមព្រេងព្រិណ។

ទីឧបាលីវិន័យធរវត្តតាមិម    អានន្ទគឺអាចារ្យគិមវត្តពិភិត
ទីកស្សបព្រះត្រូវវត្តបូរពិត    ចៅគណៈសង្ឃស្ថិតស្រុកសៀមរាប។

សង្គាយនាបថមតាមវេណី    ក្នុងគម្ពីរបិដកតាមសភាព
លុះចប់ចុះពេលថ្ងៃស្រទន់ទាប    សង្ឃបានលាភក៏វិលវត្តអាត្មា។

ពេលយប់នោះមានការលេងអាប៉េ    ក្បួនឃីកេរាំឡកបកភាសា
ពួកអ្នក ស្រុកក៏មកមើលត្រៀបត្រា    សែនមហាសប្បាយលោះលាយក្រៃ។

លុះដល់ថ្ងៃ ១ រោជរួចពិធី    ឲ្យចាត់ហែព្រះគម្ពីរបិដកថ្លៃ
ចូលដំកល់តាំងទុកនៅហោត្រៃ    សម្រាប់នៃកុលបុត្រអ្នកសិក្សា។

ថ្ងៃ ២រោជពួថាច័ក្រពង្ស    ក្រសាលស្រះស្រង់ទិសបច្ឆិមា
ឯខ្ញុំបាទក៏នាំភៀនយាត្រា    ទៅមើលក្នុងភារានគរធំ។

លុះដើរដល់ទួរគុមភ្នំបាខែង    ព្រៃត្រសុមបាំងសែងសែនភិរម្យ
ដើងគិរីមានសឹង្ហទាំង ២ មុម    ឈរចំអែបែចំទិសបូព៌ា។

សឹង្ហបាសានបូរាណលោកសំអាង    មើលដូចយ៉ាងសឹង្ហសត្វរាជសីហា
ធាត់ក្រអួនខ្លួនក្រអាញក្រាញដូចខ្លា    ចំអេងស្នាឈរអើតចំទើតជើង។

ខ្ញុំយល់សឹង្ហឈរនឹងពុំកម្រើក    ចង់តែលើកយកមកទុកស្រុកយើង
តែធំហួសផុតការលើកមិនឡើង    នឹងចចើងលើកយកពុំរួចឡើយ។

អនិច្ចាសឹង្ហអើយសឹង្ហបាសាន    ខ្ញុំយកទៅពុំបានណាសឹង្ហអើយ
ឯងនៅចុះឲ្យសុខកុំទុក្ខឡើយ    កម្មសឹង្ហហើយមកនៅក្នុងព្រៃស្ងាត់។

បើសឹង្ហឯងរស់ពិតជីវិតមាន    គួរជានៅសមសាន្តសន្ដានសត្វ
ស្វែងអាហារលៀងជីព្វពុំសូវខាត់    នេះមកបាត់វិញ្ញាណមានតែប្រាណ។

នឹងដើរទៅទីណាក៏ពុំកើត    នៅតែឈរចំអើតប្រចាំដាន
ស្តាយអើយស្តាយរូបសឹង្ហលោកបូរាណ    ចោលក្នុងស្ថានស្មសានអានាថា។

ខ្ញុំសម្លេទរូបសឹង្ហប្រឹងឡើងភ្នំ    ថ្មតូចធំជិតជុំជាន់រអា
ខ្ពស់ត្រឈឹងខំប្រឹងឡើងប្រវាំ    លុះដល់នាកំពូលគីរីស្ថាន។

លើបាខែងលោកតែងជាសថូប    មានរួតរូប ៥ ជាន់ជាដានៗ
ខាងបូព៌ាមានប្រាង្គណ៍ទាំង ៤ ស្ថាន    វិចិត្រដោយបាសានឥដ្ឋសិលា។

ខាងមុខប្រាង្គណ៍មានល៉ាយព្រះបាទព្រះ    វាលស្រឡះពុំមានគ្រិះលេខា
ដាប់ទំលុះធ្លុះចុះក្នុងសិលា    ខាងលើលោកតាំងជាវិហារបាំង។

តែវិហារនោះឯងលោកតែងថ្មី    ធ្វើដោយឈើដោយឬស្សីប្រកស្បូវភ្លាំង
ទីបូរាណមានតែរណ្តៅតាំង    ថ្មរឹងតាំងនៅបណ្តូលគោលសីលា។

ពុទ្ធបាទខ្នាតជ្រៅជុំវៅបាន ប្លាយហាត់ខ្នាតបណ្តោយ ៤ ហត្ថា
ទទឹងសោតពីរហត្ថជាមាត្រា ក្នុងបាទាលាយលក្ខណ៍កងច័ក្រជុំ។

លោកវិចិត្របិទមាសវិលាសលឿង មើលរុងរឿងគួរយើងឡើងបង្គំ
សព្វថ្ងៃមានលោកឃួនគេជាជំ នៅថែទាំពិភក្តីរក្សាស្ថាន។

ខ្ញុំយល់ព្រះពុទ្ធបាទអាណាថចិត្រ គិតដល់អង្គអគ្គនិដ្ឋព្រះទ្រង់ញាណ
កាលព្រះអង្គស្តេចនឹងចូលនិព្វាន ព្រះទ័យមានមេត្តាដល់នរៈជាតិ។

សត្វឯក្រោយពុំបានយល់សាស្តា បានទាន់តែសាស្នាបរមនាថ
ទើបប្រតិស្ឋានព្រះពុទ្ធបាទ នឹងឱវាទឲ្យប្រោសអស់សត្វផង។

ឱព្រះគុណបានបុណ្យលន់វិសេស ទ្រង់កំចាត់កិលេសជាគ្រឿងហ្មង
បាននិព្វាននៅមានព្រះទ័យចង ដំកល់បាទតាងស្នងព្រះពុទ្ធអង្គ។

ទុកឲ្យសត្វឯក្រោយបានបូជា ជាផ្លូវទៅសួគ៌ាថានទេពទ្រង់
សាងកុសលទាល់បានកាត់រាគបង់ មិនយូរលង់គង់បានស្ថានសុខា។

វេលានេះខ្ញុំមកដោយការខាត់ ពុំមានអ្វីប្រតិបត្តិចាត់បូជា
មានតែដៃទាំង ១០ ខ្ញុំវន្ទា ចិត្តវាចាបូជាក្នុងគ្រានេះ។

ឱព្រះបាទនេះជាព្រះជាន់ឬ ឬមួយគឺគេសាកទុកទេអែះ
ក្នុងដម្រាពុំមានតាំងភ្នំនេះ បើតាមរិះយ៉ាងសំណាកគេសាកថ្មី។

បញ្ចបាទទាំង ៥ សឹងមានដាន ឈ្មោះគេមានគ្រប់ស្ថានទាំង ៥ ទី
ភ្នំបាខែងពុំមានក្នុងព្រះគម្ពីរ ជាក់ជាទីកើតក្រោយដោយនិយម។

ខ្ញុំវន្ទាព្រះបាទស្រេចលាចុះ ដម្រង់ឆ្ពោះកាត់ទៅមើលនគរធំ
ផ្លូវផ្លាថ្នល់សឹងឈើម្លុបត្រសុម គេរំលំហាត់ត្រង់នគរា។

លុះដើរដល់ខ្លោងទ្វារនគរធំ សុទ្ធសឹងដុំថ្មជិតប្រកិតគ្នា
កំពូលខ្ពស់សិនសេសដោយគណនា ចំលាក់ជារូបទេពប្រណម្យដៃ។

កំពូលលើឈើដុះទំលុះចាក់ ថ្មរូសជ្រុះធ្លាក់ខ្ចាយរាយដោយព្រៃ
នៅតែរាងដូចយ៉ាងព្រះប្រាង្គណ៍ជ័យ ចូលអាស្រ័យចុះមនុស្សជាងរយនាក់។

ផ្ទៃកំពែងតែងដោយថ្មក្រៀមក្រាស បូកដីដាសពាសប៉ះឡើងថ្នាក់ៗ
កម្រាស់ក្រាស់ប្រម៉ាណពាព្យាមជាក់ ធំអាណាក់វែងអនេកលើសគណនា។

ក្រៅនគរតែងគូក្រសិនសាយ មើលវែងឆ្ងាយឱបអមនគរា
តែឥឡូវស្បាតជិតដោយព្រឹក្សា បិទគង្គាកើតជាត្រើបតាប់តាន់។

មើលខ្លោងទ្វារពណ៌នាពុំអស់ក្បួន ពេលក៏ជួនទៀបទោរព្រះសុរិយ័ន
ខំកាត់ចូលបូរីដោយបន្ទាន់ ដល់ប្រាសាទបាយ័នរាជភិរម្យ។

ប្រាង្គណ៍បាយ័នលោកសាងជាប្រាង្គណ៍មូល មានកំពូលប្រាង្គណ៍ចេញជា ៤ មុម
ក្នុងកំពូលមួយៗ ឆ្លាក់រូបព្រហ្ម បួនៗជុំគ្រប់ប្រាង្គណ៍ច្រូងច្រាងក្រៃ។

ឯរោងទងជុំវិញជ្រុងកែងកាត់ ទ្វារលោកចាត់កាត់មួយទ្វារ ១ នៃ
ក្នុងឡប់ឡែបែមុខទៅទីទៃ ចតុរស្សស្មើផ្ទៃបីជាន់សាយ។

ឱប្រាង្គណ៍នេះមើលទៅសំបើមលន់ ខ្ញុំគន់ៗ គិតទៅគួរតែស្តាយ
ប្រាង្គណ៍នេះតើដាក់អ្វីពីព្រេងនាយ តាមបរិយាយគឺដាក់ភាពយោនី។

គឺកាលដើមកាន់សាសនាព្រាហ្មណ៍ ប្រព្រឹត្តតាមដម្រាព្រះសូលី
យកយោនីឧមាភោគវតី ជាសិរីសួស្តីតាំងបូជា។

គេយល់ថាមនុស្សយើងក្នុងធរណី កើតចេញពីយោនីនាងឧមា
នាងជាម្តាយមានគុណទាំងលោកា ទើបនាំគ្នាសាងជាកំណើតហោង។

បើមានការមង្គលចំរើនឫក្ស ព្រាហ្មណ៍យកទឹកស្រោចភាពបង្ហូរត្រង
មកប្រសិទ្ធីស្រោចអស់មហាជនផង បំបាត់ក្តីសៅហ្មងចាកឥន្ទ្រីយ៍។

ភាសាព្រាហ្មណ៍គេកាន់ដម្រាសែ    ទើបកែខែចម្លងរូបយោនី
សាងប្រាង្គណ៍នេះតាំងជាមន្ទីរទី    លោកសញ្ញីឲ្យហៅជាបាយ័ន។

ឯសព្ទ-បា-នោះថាមូតមួយៗ    តាមដំរួយសព្ទ-បា-គឺមួយខណ្ឌ
យ័នសព្ទនេះពុំមែនជាលេខយន្ត    កុំប្រកាន់យន្តលេខតាមភាសិត។

សព្ទយ័តនេះគឺជាភាសាព្រាហ្មណ៍    មានក្នុងក្បួនសព្ទនាមប្លែងសង្ស្ក្រឹត
ខ្ញុំមើលៗ បាយ័នក៏តូចចិត្ត    នឹកអាណិតដល់ក្សត្រពីបូរាណ។

លោកមានបុណ្យកសាងប្រាង្គណ៍បាយ័ន    ទុកក្នុងខណ្ឌនិវេសនៃក្សត្រក្សាន្ត
មានទេសកាលក៏ឡើងប្រតិស្ឋាន    ស្រោចស្របប្រាណដោយទឹកនាងឧមា។

សែនរុងរឿងថ្កើងបុណ្យថ្កើងកេរ្តិ៍ឈ្មោះ    កិត្តិសព្ទឮសុះសព្វភារា
បរទេសរាជកោតខ្លាចឡើងវន្ទា    រាស្ត្រប្រជាសឹងក្សាន្តសំរានកាយ។

ឥឡូវផ្ទះនិវេសទៅជាព្រៃ    ទាំងប្រាង្គណ៍ជ័យក៏ដល់ក្តីអន្តរាយ
ឃើញតែស្នាដៃធ្វើបែបឡែបខាយ    ស្តាយអើយស្តាយមិនគួរមកច្នេះណា។

ទីខាងជើងមានវត្តលោកសង្ឃនៅ    ព្រះនាមហៅព្រះងោកលោកលេខា
ឱព្រះងោកៗមែនឬយ៉ាងណា    ឮគេថាយល់ជាអស្ចារ្យក្រៃ។

ខ្ញុំទៅមើលពុំឃើញព្រះលោកងោក    គិតប្រយោគយល់ថាព្រះម្ចាស់ថ្លៃ
រូបព្រះធំលន់លើសព្រះដទៃ    ឯងរំពៃមើលងុបដូចងាកមក។

វត្តមួយខាងបស្ចិមគ្មានលោកសង្ឃ    កុដិវិហារខូចបង់គ្មានទីជ្រក
វត្តនោះឯងគេហៅវត្តគោកធ្លក    តនោះមកវត្តថ្បូងចោលដូចគ្នា។

វត្តនោះហៅព្រះឥន្ទទេពកោសី    អង្គព្រះដីក៏ធំសមរូបា
កុដិវិហារបាំងព្រះគ្មានឡើយណា    អនិច្ចាមើលទៅសម្ភេទក្រៃ។

ឱអង្គព្រះឥន្ទទេពកោសីអើយ    មិនគួរឡើយមកនៅកណ្តាលព្រៃ
អាប់រាសីដោយសែងហែងដោយថ្ងៃ    ទីអាស្រ័យពុំមានក្សាន្តព្រះកាយ។

បើព្រះអង្គទៅគង់ស្រុកខ្ញុំវ៉ា    ខ្ញុំនឹងសាងសាលាវិហារថ្វាយ
ទាំងគ្រឿងតុគ្រឿងតាំងឲ្យឆើតឆាយ    ដូចជាព្រះទាំងឡាយស្រុកព្រះដំបង។

គ្រាន់និមន្តផន់លើកទៅពុំបាន    ព្រោះធំហួសប្រមាណធ្ងន់កន្លង
បើអង្គតូចទៅវ៉ានឹងរ៉ាប់រង    ដាក់ដឹកឆ្លងមកស្រុកទុកបូជា។

ឱលោកណាសទ្ធាសាងព្រះនេះ    ម្តេចមិនរិះគ្រោះមើលដោយបញ្ញា
កាលស្រុកដីមិនផុតក្តីអនិច្ចា    មកគិតថានិច្ចំតាំងទៀងទាត់។

កាលប្រទេសរុងរឿងធ្វើតាមចិត្ត    ដល់ប្រទេសវិបរិតកើតវិបត្តិ
ព្រះដីធំនឹងរំកិលក៏កើតខាត់    តោងចាំកាត់ចិត្តចោលទុកច្នេះណា។

បើយ៉ាងព្រះតូចៗ លួមយករួច    តែដល់ស្រុកខាត់ខូចដូចម្តេចម្តា
ចង់រំលៀកក៏បានដូចចិន្តា    ចុះដម្រាធំខូចតូចមិនខាត់។

ដូចរាស្ត្រទាសតាំងឡើងជានាហ្មឺន    ប្រព្រឹត្តកឺនហួសការរាជបញ្ញត្តិ
នឹងដកចេញចាកទីក៏មិនខាត់    តែមហាក្សត្រវិបត្តិដកពុំបាន។

តោងចាំនៅទៅតាមយថាកម្ម    ទុក្ខក៏ទ្រាំទោសក៏ទ្រាំទម្រាំក្សាន្ត
ដូចព្រះអង្គឥន្ទទេពជាបែបមាន    ក្សាន្តពុំបានព្រោះប្រាណធំលើសគេ។

អនិច្ចាសាស្នាព្រះជិនវង្ស    ពុំស្ថិតស្ថេរចេរលង់ក្នុងនគរេ
ជាបុណ្យបាបអ្វីពីបុព្វេ    បានជាប្រែបូរីព្រៃដូច្នេះ។

ស្រុកនេះសូន្យតើសូន្យពីរាជណា    ពង្សាវតារដម្រាងឯណាអែះ
នឹងបានមើលឲ្យដឹងរាជនោះនេះ    ខ្ញុំនឹងគ្រេះឲ្យត្រូវតាមល្បាក្សត្រ។

ខ្ញុំគន់មើលវត្តពាស្រេចចរចេរ    ទៅមើលរាជមន្ទីរចក្រវត្តិ
នៅខាងជើងព្រះងោកលោកចែងចាត់    ខឿនចង្វាត់ខ្វាត់ខ្វែងវែងវឹង។

ប្រាង្គណ៍ប្រាសាទបែកបាក់ធ្លាក់ខ្ទេចខ្ទី នៅតែទីគ្រិះក្រោមកាត់ទទឹង
មុខប្រសានស្ពានរាបភាពដាបឹង ដើងជណ្ដើរដើរមានសឹង្ហឈរប្រឹងប្រែង។

ឯផ្ទៃផ្ដែរឆ្លាក់រូបរឿងក្បួនខេន ជិះគជេន្ទ្រហែស្នួជាជួរវែង
ខាងជ្រុងៗរូបគ្រុឌឈរចំទែង ខ្លះសម្ដែងចាប់វាសុក្រីក្រោយ។

មុខព្រះលានមានប្រាង្គណ៍ជាកាត់ៗ ហៅប្រសាទសួព្រាត់ខ្ពស់ត្រសាយ
ខ្ញុំយល់ៗ នឹកកោតគេអំបាយ ប្រាង្គណ៍ខ្ពស់ឆ្ងាយចងព្រាត់ហ៊ានសួរបាន។

ទីខាងក្រោយប្រាសាទទៅបាពួន មើលក្បាច់ក្បួនឡប់ឡែជាដានៗ
ឱបាពួននួននាងក្នុងវាំងស្ថាន ចូលកំសានលេងពួនបន្លែងអង្គ។

ទីខាងជើងខ្លោងទ្វារមានគ្រិះគ្រែ ជាថ្នាក់ហែសឹងរួតហួតហៀនហង្ស
លើមន្ទីរសាងរូបចក្រពង្ស ស្ដេចគំលង់គង់នៅប្រចាំទី។

ខ្ញុំយល់រូបព្រះបាទសង្ខច័ក្រ គេសាកដាក់ជាឡាក់រាជធានី
កើតសម្ដេទវេទនាសលសែនទ្វី មិនគួរទីមកកើតវិបត្តិច្នេះ។

ឮដម្រាបរម្យរាពីបូរាណ ជាព្រះចមក្សត្រក្សាន្តនគរនេះ
ប្រហារនាគឈាមនាគផ្សប់ផ្សាយឆែះ ត្រូវព្រះកាយកើតប្រែះប្រែជាឃ្លង់។

មើលពុំជាវេទនាពន់ប្រមាណ ឥសីសានមកប្រស់ច័ក្រពង្ស
ស្ដេចពុំជឿតាមពាក្យឥសីសង្ឃ ទើបព្រះអង្គបង់ការអាសារកាយ។

ឥសីខឹងផ្ដាសារាជនិវេស ចៅប្រទេសក៏លុះក្ដីអន្តរាយ
បានជាទីស្រុកនេះកើតខ្ចាត់ខ្ចាយ ដោយបរិយាយដៅៗ ពុំពិស្ដារ។

ខ្ញុំត្រេះៗនឹកតេះស្ដេចគំលង់ ព្រះទ័យទ្រង់មានះអហង្ការ
កើតហេតុអ្វីនឹងនាគទើបប្រហារ ឲ្យខូចស្រុកអាសារស្នាដៃខ្លួន។

គួរឬក្រុងនគរសេប្រទេសធំ ប៉មកំផែងជិតជុំដ៏មាំមួន
សត្រូវណានឹងអាចចូលមកកួន តែគិតទៅចុះក្បួនព្រះត្រៃលក្ខណ៍។

សព្វសង្ខារមិនថាទាំងស្រុកដី ទួបូរិសាយសព្វគ្រប់ដំណាក់
ទុកជាចេះយ៉ាងណាក៏គង់ធ្លាក់ អញ្ជើញអ្នកមើលស្ដាប់ចាប់អារម្មណ៍។

នគរធំបរមបូរាណរាជ មើលគួរខ្លាចសឹងព្រៃស្រោងស្រាងជុំ
មានអ្នកស្រុកតាំងនៅជាដុំៗ រកស៊ីតាមនិគមអ្នកជនបទ។

រយៈផ្លូវទៅដល់នគរធំ ដោយនិយមវាស់ពីនគរវត្ត
ប្រមាណបាន ៩០ សិនប្រាកដ ចូរកំណត់កត់ចុះលោករាល់គ្នា។

ក្រែងបានទៅនឹងដាយដឹងទិសទី រាជធានីបូរាណទិសឧត្តរា
តែឥឡូវបារាំងគេកាប់ឆ្ការ ទំនងជាយូរទៅគង់សប្បាយ។

ខ្ញុំដើរគន់ដើរកាត់នគរធំ ពុំបានជុំនគរទេលោកាយ
ពេលក៏ជួនសូរិយេប្រើព្រះឆាយ ក៏រៀបកាយវិលមកសៀមរាបវិញ។

លោកចៅហ្វាយ លោកធំ លោកស័ក្ដិបី សូរេចការចក្រីក្រុងភ្នំពេញ
បង្គំលាវិលព្រះដំបងវិញ ខ្ញុំក៏អស់ក្ដីម្នេញការលោកីយ៍។

ដល់មកស្រុកសាន្តសុខឥតទុក្ខា ដោយអំណាចច័ក្រាគ្របកេសី
ទាំងគុណកែវរតន៍ត្រៃថ្លៃទាំងបី ជួយចំរើនរាសីឥតហ្មងសៅ។

រឿងនីរាសប្រកាសតែប៉ុណ្ណេះ សូមទុកស្លែះប្រាវព្ធបញ្ឈប់នៅ
គ្រាន់នឹងតែងតអង្គព្រះចមចៅ កាលស្ដេចនៅពុំទាន់វិលភ្នំពេញ។

ខ្ញុំលាហើយពុំដឹងក្រោយយ៉ាងណា រាជកិច្ចាពុំទាន់ប្រកាសចេញ
ហេតុដូច្នោះទុកឲ្យប្រាជ្ញភ្នំពេញ គេតែងចេញតរឿងព្រះចក្រី។

ខ្ញុំឥន្ទាចារ្យចែងតែងពុំបាន ព្រោះគ្មានដានលំអានយោគសេចក្ដី
ហេតុនោះសូមមេត្តាប្រោសប្រណី ខ្ញុំបញ្ចប់សេចក្ដីតែប៉ុណ្ណេះ។

សូមទោសលោកមេធីករីជាតិ
កុំឧបវាទពាក្យកាព្យខ្ញុំតែងនេះ
សូមដម្រូវឲ្យត្រូវតាមលោកចេះ
បើមិនផេះកុំបើកលើកចូលចេញ។

កុំប្រមាទពាក្យកាព្យថាតែងងាយ
យារមុខតាមនិយាយដាក់បំពេញ
បើមិនចេះពាក្យស្រួយខ្យល “រ” មិញ
ឲ្យដេកវិញជាជាងកុំតែងឡើយ។

មួយបើអ្នកឯណាចង់ចម្លង
តាមទំនងនិរាសនេះលោកអើយ
ចូលរាំងខ្យល់ រ-ល-ជាត្រើយ
តែបាត់ហើយខូចដល់ខ្លុំអ្នកតែង។

មួយស្រះ “ៃ”បំភ្លែនឹងស្រះ“ី”
វិសញ្ញនីខ្យល់ស លោកសម្តែង
កុំឲ្យចូលយារមុខទង្គុកឯង
ឲ្យនៅតាមកន្លែងទីដោយខ្លួន។

ពាក្យសំយោគការន្តវិធីសព្ទ
ចូលលំដាប់រ៉ាប់គ្នាទៅតាមជួន
យោគសេចក្តីតាំងមុខឲ្យមាំមួន
រកចុងជួនមេកាព្យសភាពអឺយ។៚